អភិបាលរាជធានី ខេត្តត្រូវជូនដំណឹងជាសាធារណៈអំពីពេលវេលានិងទីកន្លែងនៃកិច្ចប្រជុំផ្សព្វផ្សាយ។ សេចក្តីជូនដំណឹងនេះ ត្រូវបិទឱ្យសាធារណជនដឹង យ៉ាងតិច ៣ (បី) ថ្ងៃ មុនបើកកិច្ចប្រជុំផ្សព្វផ្សាយក្នុងកន្លែងដែលងាយឃើញ នៅក្នុងភូមិ ឬនៅទីតាំងធ្វើការវិនិច្ឆ័យផ្ទាល់។ សេចក្តីប្រកាសត្រូវតែផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព ក្នុងទីតាំងធ្វើការវិនិច្ឆ័យ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន។

កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យ ដែលមានលក្ខណៈជាប្រព័ន្ធត្រូវរៀបចំធ្វើនៅក្នុងទីតាំងធ្វើការវិនិច្ឆ័យ។ ក្នុងកិច្ចប្រជុំនោះ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬ តំណាងគណៈកម្មការរដ្ឋបាលត្រូវពន្យល់ពីដំណើរការនៃការវិនិច្ឆ័យ បំភ្លឺពីបញ្ញាច្បាប់ និងឆ្លើយរាល់សំណួរទាក់ទងនឹងការវិនិច្ឆ័យដែលបានលើកឡើង។

កិច្ចប្រជុំបន្ថែមសម្រាប់ថ្នាក់ភូមិ នឹងត្រូវបានរៀបចំប្រសិនបើមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬអាជ្ញាធរមូលដ្ឋានចាត់ទុកថាជាការចាំបាច់។

**មាត្រា ៧ .- ថ្មី**

មន្ត្រីកំណត់ព្រំដីត្រូវជូនដំណឹងដល់ថ្នាក់ដឹកនាំមូលដ្ឋានអំពីការកំណត់ព្រំដីក្នុងតំបន់ធ្វើការវិនិច្ឆ័យ ពេលវេលា និងទីកន្លែងដែលនឹងចាប់ផ្តើមធ្វើការវិនិច្ឆ័យឱ្យបានមុន ៣ (បី) ថ្ងៃ យ៉ាងតិច។ សេចក្តីជូនដំណឹងតម្រូវឱ្យជនដែលពាក់ព័ន្ធមកចង្អុលបង្ហាញព្រំប្រទល់នៃអចលនវត្ថុរបស់ខ្លួនតាមរបៀប ដែលបានបញ្ជាក់ក្នុងសេចក្តីប្រកាសជូនដំណឹង។

បន្ទាប់មក មន្ត្រីកំណត់ព្រំដីដែលបានទទួលការណែនាំពីអ្នកគ្រប់គ្រងការងារតំបន់វិនិច្ឆ័យត្រូវកំណត់ព្រំប្រទល់អចលនវត្ថុទាំងអស់ដែលបង្កើតបានជាក្បាលដីក្នុងប្លង់សុរិយោដី។ ក្នុងរយៈពេលធ្វើការកំណត់ព្រំប្រទល់ក្បាលដី មន្ត្រីកំណត់ព្រំដីត្រូវគោរពគោលការណ៍ ដូចខាងក្រោម ÷

ក-បើកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលជាប់ព្រំមានវត្តមាន ហើយព្រមព្រៀងលើព្រំប្រទល់ នោះព្រំប្រទល់នឹងត្រូវបានកំណត់យោងតាមការព្រមព្រៀង។

ខ-បើការព្រមព្រៀងដែលរៀបរាប់ក្នុងចំណុច (ក) នៃមាត្រានេះ មិនអាចធ្វើទៅបានឬមានកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលនៅជាប់ព្រំណាមួយអវត្តមាន នោះព្រំប្រទល់ត្រូវកំណត់នៅលើដីតាមឯកសារដែលមាន និងភស្តុតាងជាលក្ខណៈរូប ជាលាយល័ក្ខណ៍អក្សរ ឬចម្លើយផ្ទាល់មាត់ ទាក់ទងនឹងព្រំដី។

គ-ចំពោះក្បាលដីដែលមានព្រំប្រទល់ជាប់នឹងដីសាធារណៈឬក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ព្រំប្រទល់ក្បាលដីត្រូវកំណត់ដោយអនុលោមតាមចំណុច(ក)ឬ(ខ)នៃកថាខណ្ឌ ទី ២ មាត្រា ៧ ថ្មីនៃអនុក្រឹត្យនេះ។

ឃ-វិវាទទាំងអស់អំពីព្រំប្រទល់ដែលមិនអាចដោះស្រាយបានក្នុងពេលកំណត់ព្រំដី ត្រូវបញ្ជូនទៅធ្វើការសម្រុះសម្រួល និងដោះស្រាយវិវាទក្រោមមាត្រា ១២ នៃអនុក្រឹត្យនេះ។

**មាត្រា ១១ .- ថ្មី**

ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យដែលរួមមាន ប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីត្រូវមានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៅកន្លែងដែលងាយមើលឃើញសម្រាប់ការអង្កេតជាសាធារណៈនៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ។

អាជ្ញាធររាជធានី ខេត្ត ត្រូវផ្សាយដំណឹងអំពីការបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យ តាមសំណើរបស់គណៈកម្មការរដ្ឋបាល។

ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ អាចកែតម្រូវការខុសឆ្គង ឬការភ្លេចភ្លាំងណាដែលមិនជះឥទ្ធិពលដល់ផលប្រយោជន៍ត្រឹមត្រូវស្របច្បាប់ នៃជនណាមួយ។ ការកែតម្រូវផ្សេងៗ ក្នុងឯកសារនៃការវិនិច្ឆ័យ អាចធ្វើបានដរាបណាមានការយល់ព្រមពីជនពាក់ព័ន្ធ ដែលទទួលឥទ្ធិពលពីការកែតម្រូវនោះ។

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## បែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឲ្យជនបរទេសមិនមែនអន្តោប្រវេសន្ត ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

- បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.–**

អនុក្រឹត្យនេះមានគោលបំណងពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងជនបរទេសមិនមែនអន្តោប្រវេសន្តនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.–**

អនុក្រឹត្យនេះមានគោលដៅកំណត់បែបបទចូល ចេញ និងស្នាក់អាស្រ័យចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣.–**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## បែបបទសម្រាប់ការចូល ចេញព្រះរាជាណាចក្រកម្ពុជា

**មាត្រា៤.–**

ជនបរទេសមិនមែនអន្តោប្រវេសន្តដែលមានបំណងចូលមកព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យស្នើសុំទិដ្ឋាការចូលតាមរយៈទីកន្លែងដូចខាងក្រោម៖

-ស្ថានបេសកកម្មការទូត ឬស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលកិត្តិយសនៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស

-ច្រកទ្វារអន្តរជាតិ

-គេហទំព័រទិដ្ឋាការអេឡិចត្រូនិចសម្រាប់ប្រភេទទេសចរណ៍។

**មាត្រា៥.–**

ចំពោះប្រទេសដែលមានចុះកិច្ចព្រមព្រៀងលើកលែងទិដ្ឋាការជាមួយព្រះរាជាណាចក្រកម្ពុជា អ្នកកាន់

លិខិតឆ្លងដែនការទូត ផ្លូវការ ពិសេស និងធម្មតា ត្រូវបានកំណត់ការស្នាក់នៅទៅតាមកិច្ចព្រមព្រៀងនោះ។ ក្នុងករណីជនបរទេសកាន់លិខិតឆ្លងដែនគ្រប់ប្រភេទ មានបំណងស្នាក់នៅលើសពីរយៈពេលកំណត់ក្នុងកិច្ចព្រមព្រៀង តម្រូវឲ្យស្នើសុំទិដ្ឋាការតាមប្រភេទដូចមានចែងក្នុងមាត្រា៩ នៃអនុក្រឹត្យនេះ។

**មាត្រា៦.-**

ការស្នើសុំទិដ្ឋាការចូលរបស់ជនបរទេសមិនមែនអន្តោប្រវេសន្ត នៅស្ថានបេសកកម្មការទូត ឬស្ថានអគ្គកុងស៊ុល និងស្ថានកុងស៊ុលកិត្តិយសនៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស និងនៅច្រកទ្វារអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជាត្រូវបំពេញបែបបទដូចតទៅ៖

១-បំពេញពាក្យសុំទិដ្ឋាការចូល។

២-បង្ហាញលិខិតឆ្លងដែន ឬឯកសារធ្វើដំណើរផ្សេងៗមានតម្លៃស្មើ ដែលត្រូវមានសុពលភាពយ៉ាងតិច៦(ប្រាំមួយ)ខែ។

៣-ផ្ដល់រូបថតទំហំ ៤ x ៦ ចំនួន១(មួយ)សន្លឹក។

៤-ជនបរទេសដែលប្រើប្រាស់លិខិតឆ្លងដែនធ្វើដំណើររួមជាមួយឪពុកម្ដាយ ឬអ្នកអាណាព្យាបាល អាចបំពេញបែបបទនិងចុះឈ្មោះរួមជាមួយឪពុកម្ដាយ ឬអ្នកអាណាព្យាបាលរបស់ខ្លួនប៉ុន្តែត្រូវបង់អាករ ដូចជនបរទេសដែលប្រើប្រាស់លិខិតឆ្លងដែនដាច់ដោយឡែកដែរ។

៥-បង់អាករតាមការកំណត់ដូចមានចែងក្នុងមាត្រា១៦ នៃអនុក្រឹត្យនេះ។ អាករទិដ្ឋាការនេះមិនត្រូវបានសងវិញទេ ទោះក្នុងករណីនៃការស្នើសុំទិដ្ឋាការនោះ ត្រូវបានបដិសេធក៏ដោយ។

ចំពោះការស្នើសុំទិដ្ឋាការប្រភេទ K សាមីជនត្រូវភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធបញ្ជាក់ថាពិតជាមានសញ្ជាតិខ្មែរពីកំណើត។

**មាត្រា៧.-**

ការស្នើសុំទិដ្ឋាការចូលរបស់ជនបរទេសមិនមែនអន្តោប្រវេសន្ត តាមរយៈគេហទំព័រទិដ្ឋាការអេឡិចត្រូនិចសម្រាប់ប្រភេទទេសចរណ៍ ត្រូវបំពេញបែបបទដូចតទៅ៖

១-ចូលទៅគេហទំព័រទិដ្ឋាការអេឡិចត្រូនិច ដែលកំណត់ដោយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

២-បំពេញពាក្យស្នើសុំទិដ្ឋាការចូល និងបញ្ចូលរូបថត។

៣-លិខិតឆ្លងដែនត្រូវមានសុពលភាពយ៉ាងតិច៦(ប្រាំមួយ)ខែ។

៤-ជនបរទេសដែលប្រើប្រាស់លិខិតឆ្លងដែនធ្វើដំណើររួមជាមួយឪពុកម្ដាយ ឬអ្នកអាណាព្យាបាល អាចបំពេញបែបបទនិងចុះឈ្មោះរួមជាមួយឪពុកម្ដាយ ឬអ្នកអាណាព្យាបាលរបស់ខ្លួន ប៉ុន្តែត្រូវបង់អាករដូចជនបរទេសដែលប្រើប្រាស់លិខិតឆ្លងដែនដាច់ដោយឡែកដែរ។

៥-បង់អាករតាមបណ្ណឥណទាន។

អាករទិដ្ឋាការនេះត្រូវបានបង្វិលសងវិញក្នុងករណីអាជ្ញាធរអន្តោប្រវេសន៍នៅច្រកទ្វារអន្តរជាតិ ពុំអនុញ្ញាតឲ្យចូលដោយមូលហេតុប្រព័ន្ធបច្ចេកទេសនៃទិដ្ឋាការអេឡិចត្រូនិច ឬព័ត៌មានមិនគ្រប់គ្រាន់។

**មាត្រា៨.-**

ការស្នើសុំទិដ្ឋាការចេញរបស់ជនបរទេសមិនមែនអន្តោប្រវេសន្ត ត្រូវបំពេញបែបបទដូចតទៅះ

១-បំពេញពាក្យសុំទិដ្ឋាការចេញ។

២-បង្ហាញលិខិតឆ្លងដែន ឬឯកសារណាមួយដែលមានតម្លៃស្មើ។

៣-ផ្តល់រូបថតទំហំ ៤ x ៦ ចំនួន២ (ពីរ) សន្លឹក។

៤-ភ្ជាប់មកជាមួយនូវះ

-ពាក្យប្តឹងនៃការបាត់បង់ឬខូចលិខិតឆ្លងដែន ដែលទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច។ ប្រទេសដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែពុំមាននិវេសនដ្ឋាននៅព្រះរាជាណាចក្រកម្ពុជាអាចធ្វើលិខិតឆ្លងដែនថ្មីឬឯកសារធ្វើដំណើរដែលមានតម្លៃស្មើឲ្យពលរដ្ឋរបស់ខ្លួនប្រើប្រាស់សម្រាប់ស្នើសុំទិដ្ឋាការចេញ មកក្រសួងមហាផ្ទៃ ឬតាមរយៈផ្លូវការទូត

-លិខិតដោះលែងពីពន្ធនាគារ តាមសេចក្តីសម្រេចរបស់តុលាការ

-សំបុត្របញ្ជាក់កំណើត ឬឯកសារដែលមានតម្លៃស្មើចំពោះកូនដែលកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬឯកសារពាក់ព័ន្ធផ្សេងៗទៀតក្នុងករណីចាំបាច់។

៥-បង់អាករតាមការកំណត់ដូចមានចែងក្នុងមាត្រា១៦នៃអនុក្រឹត្យនេះ។ អាករទិដ្ឋាការនេះមិនត្រូវបានសងវិញទេ ក្នុងករណីទិដ្ឋាការនោះផុតសុពលភាព។

## ជំពូកទី៣
## ប្រភេទ សុពលភាព រយៈពេលស្នាក់នៅ និងអាករនៃទិដ្ឋាការ

**មាត្រា៩.-**

ប្រភេទទិដ្ឋាការចូល ត្រូវបានកំណត់ដូចខាងក្រោមះ

១-**ទិដ្ឋាការការទូត** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ A។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តដែលកាន់លិខិតឆ្លងដែនការទូតនិងក្រុមគ្រួសារ។

២-**ទិដ្ឋាការផ្លូវការ** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ B។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលកាន់លិខិតឆ្លងដែនផ្លូវការមកបំពេញបេសកកម្មក្នុងក្របខណ្ឌរដ្ឋ ឬក្នុងក្របខណ្ឌអង្គការអន្តរជាតិនានាដែលបានចុះអនុស្សរណៈជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

៣-**ទិដ្ឋាការចៅរីភាព** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ C។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តនិងក្រុមគ្រួសារ ដែលក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ឬក្រសួងនានាចាត់ទុកជាកិច្ចសហប្រតិបត្តិការ ឬការសម្តែងការគួរសម។

៤-**ទិដ្ឋាការឆ្លងកាត់** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ D។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តដែលជាអ្នកធ្វើដំណើរឆ្លងកាត់ អ្នកបើកបរ បុគ្គលិក និយោជិត និងកម្មករលើយានយន្ត រថភ្លើង នាវា ឬយន្តហោះ។

៥-**ទិដ្ឋាការធម្មតា** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ E។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តដែលមិនស្ថិតក្នុងប្រភេទទិដ្ឋាការណាមួយ សម្រាប់ចូល ចេញ តែមួយដង។

៦-**ទិដ្ឋាការធម្មតារយៈពេលវែង** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ E1 E2 និង E3។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះពាណិជ្ជករដែលមានបំណងចូល ចេញច្រើនដង តាមការកំណត់ជាគោលការណ៍របស់រាជរដ្ឋាភិបាល ក្នុងគោលដៅលើកតម្កើងសក្តានុពលសេដ្ឋកិច្ច និងបច្ចេកវិទ្យា។

៧-**ទិដ្ឋាការពិសេស** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ K។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះជនដែលមានសញ្ជាតិខ្មែរពីកំណើត ហើយកាន់លិខិតឆ្លងដែន ឬឯកសារធ្វើដំណើរបរទេស។

៨-**ទិដ្ឋាការអេកម៉ិក** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ KHM។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះទេសចរដែលមានបំណងធ្វើដំណើរចូលទៅក្នុងបណ្តាប្រទេសក្នុងតំបន់យុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ចអាយេយ៉ាវឌី-ចៅប្រាយ៉ា-មេគង្គ ACMECS។

៩-**ទិដ្ឋាការទេសចរណ៍** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ T។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តដែលជាទេសចរ សម្រាប់ចូល ចេញ តែមួយដង។

១០-**ទិដ្ឋាការទេសចរណ៍រយៈពេលវែង** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ T1 T2 និងT3។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះទេសចរដែលមានបំណងចូល ចេញច្រើនដង តាមការកំណត់ជាគោលការណ៍របស់រាជរដ្ឋាភិបាលក្នុងគោលដៅលើកតម្កើងសក្តានុពលទេសចរណ៍និងវប្បធម៌។

**មាត្រា១០.-**

ប្រភេទទិដ្ឋាការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្ន ត្រូវបានកំណត់ដូចតទៅ៖

១-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលទទួលបានទិដ្ឋាការ A កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $A_{EX}$។

២-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលទទួលបានទិដ្ឋាការ B កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $B_{EX}$។

៣-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលទទួលបានទិដ្ឋាការ C កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $C_{EX}$។

៤-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជានិយោជិត ពាណិជ្ជករ បុគ្គលិក ពលករ និងអ្នកប្រកបរបរផ្សេងៗដែលទទួលបានទិដ្ឋាការ E កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $E_B$។

៥-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តទូទៅ ដែលទទួលបានទិដ្ឋាការ E កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $E_G$។

៦-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជាអ្នកស្វែងយល់អាជីវកម្មដែលទទួលបានទិដ្ឋាការ E កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $E_P$។

៧-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជានិវត្តជន ដែលទទួលបានទិដ្ឋាការ E កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $E_R$។

៨-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជាសិស្សនិស្សិតដែលទទួលបានទិដ្ឋាការ E កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $E_S$។

៩-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជាអ្នកបច្ចេកទេសជំនាញដែលទទួលបានទិដ្ឋាការ E កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $E_T$។

១០-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជាពាណិជ្ជករ ដែលទទួលបានទិដ្ឋាការ E1 E2 និង E3 កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $E1_{EX}$ $E2_{EX}$ និង $E3_{EX}$។

១១-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជាទេសចរ ដែលទទួលបានទិដ្ឋាការអេឡិចត្រូនិចសម្រាប់ប្រភេទទេសចរណ៍ និង KHM កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $T_{EX}$។

១២-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជាទេសចរ ដែលទទួលបានទិដ្ឋាការ T កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $T_{EX}$។

១៣-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជាទេសចរ ដែលទទួលបានទិដ្ឋាការ T1 T2 និង T3 កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $T1_{EX}$ $T2_{EX}$ និង $T3_{EX}$។

**មាត្រា១១.-**

**ទិដ្ឋាការចេញ** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $E_X$។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តដែលទើបទទួលបានលិខិតឆ្លងដែនថ្មី ឬឯកសារធ្វើដំណើរដែលមានតម្លៃស្មើផ្តល់ដោយស្ថានទូត ឬស្ថានកុងស៊ុលបរទេស ហើយសាមីខ្លួនមានបំណងចាកចេញពីព្រះរាជាណាចក្រកម្ពុជា។

ទិដ្ឋាការនេះក៏សម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលតម្រូវឲ្យចាកចេញផុតពីព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១២.-**

គំរូនិងលក្ខណៈសម្គាល់នៃប្រភេទទិដ្ឋាការនីមួយៗត្រូវសម្រេចដាក់ឲ្យអនុវត្តដោយប្រកាសអន្តរក្រសួងរវាង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៣.-**

ទិដ្ឋាការត្រូវបានកំណត់សុពលភាពគិតចាប់ពីថ្ងៃចេញទិដ្ឋាការនោះតាមប្រភេទដូចខាងក្រោម៖

| | |
|---|---|
| -ទិដ្ឋាការប្រភេទ A | មានសុពលភាពមិនលើស ៣(បី)ខែ |
| -ទិដ្ឋាការប្រភេទ B | មានសុពលភាពមិនលើស ៣(បី)ខែ |
| -ទិដ្ឋាការប្រភេទ C | មានសុពលភាពមិនលើស ៣(បី)ខែ |
| -ទិដ្ឋាការប្រភេទ D | មានសុពលភាពមិនលើស ៧(ប្រាំពីរ)ថ្ងៃ |
| -ទិដ្ឋាការប្រភេទ E | មានសុពលភាពមិនលើស ៣(បី)ខែ |
| -ទិដ្ឋាការប្រភេទ E1 | មានសុពលភាព ១(មួយ)ឆ្នាំ |
| -ទិដ្ឋាការប្រភេទ E2 | មានសុពលភាព ២(ពីរ)ឆ្នាំ |
| -ទិដ្ឋាការប្រភេទ E3 | មានសុពលភាព ៣(បី)ឆ្នាំ |
| -ទិដ្ឋាការប្រភេទ Ex | មានសុពលភាព ៧(ប្រាំពីរ)ថ្ងៃ |
| -ទិដ្ឋាការប្រភេទ K | មានសុពលភាពត្រឹមថ្ងៃផុតកំណត់នៃលិខិតឆ្លងដែន |
| -ទិដ្ឋាការប្រភេទ KHM | មានសុពលភាពមិនលើស ៣(បី)ខែ |
| -ទិដ្ឋាការប្រភេទ T | មានសុពលភាពមិនលើស ៣(បី)ខែ |
| -ទិដ្ឋាការប្រភេទ T1 | មានសុពលភាព ១(មួយ)ឆ្នាំ |
| -ទិដ្ឋាការប្រភេទ T2 | មានសុពលភាព ២(ពីរ)ឆ្នាំ |
| -ទិដ្ឋាការប្រភេទ T3 | មានសុពលភាព ៣(បី)ឆ្នាំ |

ស្ថានបេសកកម្មការទូត ឬស្ថានអគ្គកុងស៊ុលកម្ពុជានៅក្រៅប្រទេស អាចផ្តល់ទិដ្ឋាការការទូតប្រភេទ A មានសុពលភាព១(មួយ)ឆ្នាំ ចូល ចេញច្រើនដង ដល់អ្នកការទូតបរទេសប្រចាំនៅកម្ពុជាដែលពុំមាននិវេសនដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងករណីដែលទិដ្ឋាការផុតសុពលភាព ជនបរទេសដែលទទួលបានទិដ្ឋាការនេះ និងមិនទាន់បានចូល ឬចេញពីព្រះរាជាណាចក្រម្ពុជា ត្រូវដាក់ពាក្យសុំទិដ្ឋាការជាថ្មី។

**មាត្រា១៤.-**

ជនបរទេសដែលទទួលបានទិដ្ឋាការចូលព្រះរាជាណាចក្រកម្ពុជា អាចស្នាក់នៅតាមរយៈពេលដូចខាងក្រោម៖

| | |
|---|---|
| -ទិដ្ឋាការប្រភេទ A | រយៈពេល ៣(បី)ខែ |
| -ទិដ្ឋាការប្រភេទ B | រយៈពេល ៣(បី)ខែ |
| -ទិដ្ឋាការប្រភេទ C | រយៈពេល ៣(បី)ខែ |
| -ទិដ្ឋាការប្រភេទ D | រយៈពេល ៥(ប្រាំ)ថ្ងៃ |
| -ទិដ្ឋាការប្រភេទ E | រយៈពេល ១(មួយ)ខែ |
| -ទិដ្ឋាការប្រភេទ E1 | រយៈពេល ១(មួយ)ខែ |

-ទិដ្ឋាការប្រភេទ E2 រយៈពេល ១(មួយ)ខែ

-ទិដ្ឋាការប្រភេទ E3 រយៈពេល ១(មួយ)ខែ

-ទិដ្ឋាការប្រភេទ K រយៈពេលត្រឹមថ្ងៃផុតកំណត់នៃលិខិតឆ្លងដែន

-ទិដ្ឋាការប្រភេទ KHM រយៈពេល ១(មួយ)ខែ

-ទិដ្ឋាការប្រភេទ T រយៈពេល ១(មួយ)ខែ

-ទិដ្ឋាការប្រភេទ T1 រយៈពេល ១(មួយ)ខែ

-ទិដ្ឋាការប្រភេទ T2 រយៈពេល ១(មួយ)ខែ

-ទិដ្ឋាការប្រភេទ T3 រយៈពេល ១(មួយ)ខែ

ការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្នត្រូវអនុវត្តតាមការកំណត់ដូចមានចែងក្នុងមាត្រា១៩នៃអនុក្រឹត្យនេះ។

**មាត្រា១៥.–**

គោលបំណងនៃការស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជារបស់ជនបរទេសមិនមែនអន្តោប្រវេសន្តត្រូវស្របតាមប្រភេទនៃទិដ្ឋាការដែលផ្តល់ឲ្យ ឬកិច្ចព្រមព្រៀងស្តីពីការលើកលែងទិដ្ឋាការជាមួយព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៦.–**

អាករទិដ្ឋាការចូល ចេញ បែបបទ និងនីតិវិធីនៃការប្រមូលអាករនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីទទួលបានការយល់ព្រមពីប្រមុខរាជរដ្ឋាភិបាល។

## ជំពូកទី៤

## ការផ្តល់ ការបដិសេធទិដ្ឋាការចូល ចេញ និងបែបបទ រយៈពេល អាករ នៃការបន្តពេលស្នាក់នៅបណ្តោះអាសន្ន

**មាត្រា១៧.–**

ក-ស្ថានបេសកកម្មការទូត ឬស្ថានអគ្គកុងស៊ុល និងស្ថានកុងស៊ុលកិត្តិយសនៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេសមានសមត្ថកិច្ចផ្តល់ ឬបដិសេធទិដ្ឋាការគ្រប់ប្រភេទលើកលែងទិដ្ឋាការអេឡិចត្រូនិចសម្រាប់ប្រភេទទេសចរណ៍។

ខ-ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិមានសមត្ថកិច្ចៈ

-ផ្តល់ ឬបដិសេធទិដ្ឋាការអេឡិចត្រូនិចសម្រាប់ប្រភេទទេសចរណ៍

-បន្តការស្នាក់នៅបណ្តោះអាសន្ន និងកំណត់ការចូល ចេញមួយ ឬច្រើនដង ចំពោះទិដ្ឋាការប្រភេទ A B និង C។

គ-ក្រសួងមហាផ្ទៃមានសមត្ថកិច្ចៈ

-ផ្តល់ឬបដិសេធទិដ្ឋាការគ្រប់ប្រភេទនៅតាមបណ្តាច្រកទ្វារអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា លើកលែងទិដ្ឋាការអេឡិចត្រូនិចសម្រាប់ប្រភេទទេសចរណ៍ និង KHM

-បន្តការស្នាក់នៅបណ្តោះអាសន្ននិងកំណត់ការចូល ចេញមួយ ឬច្រើនដង ចំពោះទិដ្ឋាការគ្រប់ប្រភេទ លើកលែងប្រភេទ A B និង C។

**មាត្រា១៨.-**

ការចូល ចេញមួយ ឬច្រើនដងសម្រាប់ទិដ្ឋាការគ្រប់ប្រភេទត្រូវបានកំណត់ដូចតទៅៈ

-ទិដ្ឋាការប្រភេទ A ចូល ចេញ ច្រើនដង

-ទិដ្ឋាការប្រភេទ B ចូល ចេញ មួយដង

-ទិដ្ឋាការប្រភេទ C ចូល ចេញ មួយដង

-ទិដ្ឋាការប្រភេទ D ចូល ចេញ មួយដង

-ទិដ្ឋាការប្រភេទ E ចូល ចេញ មួយដង

-ទិដ្ឋាការប្រភេទ E1 ចូល ចេញ ច្រើនដង

-ទិដ្ឋាការប្រភេទ E2 ចូល ចេញ ច្រើនដង

-ទិដ្ឋាការប្រភេទ E3 ចូល ចេញ ច្រើនដង

-ទិដ្ឋាការប្រភេទ Ex ចេញមួយដង

-ទិដ្ឋាការប្រភេទ K ចូល ចេញ ច្រើនដង

-ទិដ្ឋាការប្រភេទ KHM ចូល ចេញ មួយដង

-ទិដ្ឋាការប្រភេទ T ចូល ចេញ មួយដង

-ទិដ្ឋាការប្រភេទ T1 ចូល ចេញ ច្រើនដង

-ទិដ្ឋាការប្រភេទ T2 ចូល ចេញ ច្រើនដង

-ទិដ្ឋាការប្រភេទ T3 ចូល ចេញ ច្រើនដង។

**មាត្រា១៩.-**

ការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្នត្រូវបានកំណត់ដូចតទៅៈ

-ទិដ្ឋាការប្រភេទ $A_{EX}$ អាចបន្តរយៈពេលបានពី១(មួយ)ខែ រហូតដល់ចប់បេសកកម្ម

-ទិដ្ឋាការប្រភេទ $B_{EX}$ អាចបន្តរយៈពេលបានពី១(មួយ)ខែ ដល់១២(ដប់ពីរ)ខែ ម្តង រហូតដល់ចប់បេសកកម្ម

-ទិដ្ឋាការប្រភេទ $C_{EX}$ អាចបន្តរយៈពេលបានពី១(មួយ)ខែ ដល់១២(ដប់ពីរ)ខែ ម្តង

-ទិដ្ឋាការប្រភេទ D មិនអាចបន្តរយៈពេលបានទេ លើកលែងតែក្នុងករណីជាក់ស្តែងនិងចាំបាច់បំផុត សាមីខ្លួនអាចស្នើសុំបន្តរយៈពេលស្នាក់នៅដូចទិដ្ឋាការប្រភេទ $T_{EX}$

-ទិដ្ឋាការប្រភេទ $E_B$ អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ ឬ៦(ប្រាំមួយ)ខែ ឬ ១២(ដប់ពីរ)ខែ

-ទិដ្ឋាការប្រភេទ $E_G$ អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ ឬ៦(ប្រាំមួយ)ខែ តែម្តងគត់

-ទិដ្ឋាការប្រភេទ $E_P$ អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ តែម្តងគត់

-ទិដ្ឋាការប្រភេទ $E_R$ អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ ឬ៦(ប្រាំមួយ)ខែ ឬ ១២(ដប់ពីរ)ខែ

-ទិដ្ឋាការប្រភេទ $E_S$ អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ ឬ៦(ប្រាំមួយ)ខែ ឬ ១២(ដប់ពីរ)ខែ

-ទិដ្ឋាការប្រភេទ $E_T$ អាចបន្តរយៈពេលបាន២៤(ម្ភៃបួន)ខែ បន្ទាប់មកអាចបន្តបាន១២ (ដប់ពីរ)ខែ បីដងទៀត ហើយតម្រូវឲ្យចាកចេញពីប្រទេស

-ទិដ្ឋាការប្រភេទ $E1_{EX}$ អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ ឬ៦(ប្រាំមួយ)ខែ ឬ ១២(ដប់ពីរ)ខែ

-ទិដ្ឋាការប្រភេទ $E2_{EX}$ អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ ឬ៦(ប្រាំមួយ)ខែ ឬ ១២(ដប់ពីរ)ខែ

-ទិដ្ឋាការប្រភេទ $E3_{EX}$ អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ ឬ៦(ប្រាំមួយ)ខែ ឬ ១២(ដប់ពីរ)ខែ

-ទិដ្ឋាការប្រភេទ $T_{EX}$ អាចបន្តរយៈពេលបាន១(មួយ)ខែ តែម្តងគត់

-ទិដ្ឋាការប្រភេទ $T1_{EX}$ អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ តែម្តងគត់

-ទិដ្ឋាការប្រភេទ $T2_{EX}$ អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ តែម្តងគត់

-ទិដ្ឋាការប្រភេទ $T3_{EX}$ អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ តែម្តងគត់

ចំពោះការស្នើសុំបន្តរយៈពេលស្នាក់នៅទិដ្ឋាការគ្រប់ប្រភេទ លើកលែង A B និង C សាមីជនត្រូវមកបង្ហាញខ្លួនដើម្បីបំពេញបែបបទដោយផ្ទាល់នៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ។

**មាត្រា២០.-**

បែបបទស្នើសុំការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្ននៃទិដ្ឋាការគ្រប់ប្រភេទមានដូចតទៅ៖

១-បំពេញពាក្យសុំបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្ន។

២-ភ្ជាប់មកជាមួយនូវលិខិតឆ្លងដែនដែលមានសុពលភាពយ៉ាងតិច៦(ប្រាំមួយ)ខែ លើសពីរយៈពេលស្នើសុំបន្តស្នាក់នៅបណ្តោះអាសន្ន។

៣-រូបថតទំហំ ៤ x ៦ ចំនួន១(មួយ)សន្លឹក។

៤-ត្រូវបង់ ឬលើកលែងអាករតាមការកំណត់ក្នុងមាត្រា២២ នៃអនុក្រឹត្យនេះ។

៥-ចំពោះការស្នើសុំបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្ន ដែលទទួលបានពីទិដ្ឋាការធម្មតា E សាមីជនត្រូវភ្ជាប់មកជាមួយនូវ៖

ក-ទិដ្ឋាការប្រភេទ $E_B$

-លិខិតប្រកបអាជីវកម្ម និងបណ្ណប៉ាតង់ ឬ

-កិច្ចសន្យាការងារ ឬ

-ឯកសារពាក់ព័ន្ធបញ្ជាក់ថាពិតជាមានការចាំបាច់ក្នុងការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្នមែន

-ឯកសារបញ្ជាក់ថាពិតជាមានជាប់ពាក់ព័ន្ធជាសហព័ទ្ធ ឬកូន។

ខ-ទិដ្ឋាការប្រភេទ $E_G$

-ឯកសារពាក់ព័ន្ធបញ្ជាក់ពីគោលបំណងរបស់ខ្លួន។

គ-ទិដ្ឋាការប្រភេទ $E_P$

-គម្រោង ឬ

-ឯកសារពាក់ព័ន្ធបញ្ជាក់ពីគោលបំណងរបស់ខ្លួន។

ឃ-ទិដ្ឋាការប្រភេទ $E_R$

-ឯកសារ ឬលិខិតបញ្ជាក់ពីការចូលនិវត្តន៍របស់ខ្លួន

-ឯកសារបង្ហាញពីប្រាក់សោធននិវត្តន៍ពីធនាគារ ឬឯកសារពាក់ព័ន្ធផ្សេងៗ។

ង-ទិដ្ឋាការប្រភេទ $E_S$

-លិខិតបញ្ជាក់ពីគ្រឹះស្ថានសិក្សា ទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យអប់រំ

-ការធានាពីឪពុក ម្តាយ ឬអ្នកអាណាព្យាបាល ដែលបញ្ជាក់ថាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទំនុកបម្រុងថ្លៃសិក្សា ឬឯកសារពាក់ព័ន្ធផ្សេងៗ។

ច-ទិដ្ឋាការប្រភេទ $E_T$

-អាជ្ញាបណ្ណក្រុមហ៊ុន សហគ្រាស ឬអង្គភាពដែលសាមីជនកំពុងបម្រើការងារ

-កិច្ចសន្យាការងារ

-ឯកសារបញ្ជាក់ថាពិតជាមានជាប់ពាក់ព័ន្ធជាប្តី ប្រពន្ធ ឬកូន ចំពោះសហព័ទ្ធ និងកូនរបស់សាមីខ្លួន។

**មាត្រា២១.-**

ទោះក្នុងករណីលិខិតឆ្លងដែនត្រូវបានបាត់ ឬខូចទ្រង់ទ្រាយដើមក៏ដោយ ទិដ្ឋាការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្ននៅតែមានសុពលភាពដដែល។

សាមីជនត្រូវស្នើសុំមកក្រសួងមហាផ្ទៃដើម្បីផ្ទេរទិដ្ឋាការបន្តរយៈពេលស្នាក់នៅដែលនៅមានសុពលភាពនោះមកលើលិខិតឆ្លងដែនថ្មីរបស់ខ្លួនដោយមិនបង់អាករ។

**មាត្រា២២.-**

អាករនៃការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្ន បែបបទ និងនីតិវិធីនៃការប្រមូលអាករនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីទទួលបានការយល់ព្រមពីប្រមុខរាជរដ្ឋាភិបាល។

អាករគ្រប់ប្រភេទខាងលើត្រូវបង់ចូលថវិកាជាតិ។

## ជំពូកទី៥
## ការហាមឃាត់ការចូល ចេញ និងការស្នាក់នៅបណ្តោះអាសន្ន

**មាត្រា២៣.-**

ត្រូវហាមឃាត់ការចូល ចេញ និងការស្នាក់នៅបណ្តោះអាសន្នក្នុងព្រះរាជាណាចក្រកម្ពុជាចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ក្នុងករណីដូចខាងក្រោម៖

ក- ការហាមឃាត់ការចូល

១-លិខិតឆ្លងដែន ឬឯកសារធ្វើដំណើរគ្មានតម្លៃ។

២-គ្មានទិដ្ឋាការចូល លើកលែងប្រទេសដែលមានកិច្ចព្រមព្រៀងជាមួយព្រះរាជាណាចក្រកម្ពុជា។

៣-វិកលចរិត។

៤-មានឈ្មោះក្នុងបញ្ជីហាមចូលដែលកំណត់ដោយក្រសួងមហាផ្ទៃ។

៥-មានផ្ទុកជម្ងឺឆ្លងធ្ងន់ធ្ងរដែលប្រកាសដោយរាជរដ្ឋាភិបាល។

៦-កំពុងជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

៧-ប្រវត្តិនៃការធ្វើដំណើរមិនច្បាស់លាស់។

៨-គោលបំណងនៃការធ្វើដំណើរមិនច្បាស់លាស់។

៩-ខ្វះលទ្ធភាពចិញ្ចឹមខ្លួន និងក្រុមគ្រួសារគ្មានជនណាផ្សេងធានាជួយដោះស្រាយ។

១០-ក្លែងបន្លំ កោស លុប សរសេរត្រួត ឬបន្ថែមទិន្នន័យនៅលើឯកសារធ្វើដំណើរ ឬឯកសារពាក់ព័ន្ធផ្សេងៗ។

១១-ធ្លាប់បានបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា។ ការអនុញ្ញាតផ្តល់ទិដ្ឋាការឲ្យចូលវិញត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

១២-បានលួចឡើងនាវា រថយន្ត រថភ្លើង ឬយន្តហោះចូលមកព្រះរាជាណាចក្រកម្ពុជា។

១៣-ក្រសួងមហាផ្ទៃមានហេតុផលគ្រប់គ្រាន់ជឿថានឹងប្រព្រឹត្តសកម្មភាពធ្វើឲ្យខូចផលប្រយោជន៍សណ្តាប់ធ្នាប់សាធារណៈ សីលធម៌សង្គម និងធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខជាតិ អន្តរជាតិ។

ក្នុងករណីអ្នកស្នើសុំទិដ្ឋាការចូល មានមូលហេតុក្នុងចំណុចណាមួយខាងលើ អាជ្ញាធរមានសមត្ថកិច្ចក្រសួងមហាផ្ទៃ ត្រូវបញ្ជូនសាមីជនឲ្យចាកចេញផុតពីព្រះរាជាណាចក្រកម្ពុជាទៅគោលដៅដើមវិញ។

ខ- ការហាមឃាត់ការចេញ

១-គ្មានទិដ្ឋាការចេញ ។

២-សាមីជនកំពុងស្ថិតក្នុងបណ្តឹងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី។

៣-គេចវេះពីទោសទណ្ឌ ឬការទទួលខុសត្រូវរបស់ខ្លួនចំពោះមុខច្បាប់។

៤-ជនដែលក្លែងបន្លំ កោស លុប សរសេរត្រួត ឬបន្ថែមទិន្នន័យនៅលើឯកសារធ្វើដំណើរ ឬឯកសារពាក់ព័ន្ធផ្សេងៗ។

៥-មិនបង់ប្រាក់ពិន័យអន្តរការណ៍លើការស្នាក់នៅហួសរយៈពេលកំណត់ លើកលែងមានការសម្រេចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

៦-ក្រសួងមហាផ្ទៃមានហេតុផលគ្រប់គ្រាន់ជឿថា ការចាកចេញពីព្រះរាជាណាចក្រកម្ពុជារបស់ជនបរទេសរូបនោះនឹងធ្វើឲ្យខូចផលប្រយោជន៍សាធារណៈ ឬប្រជាពលរដ្ឋខ្មែរ។

ក្នុងករណីអ្នកស្នើសុំទិដ្ឋាការចេញមានមូលហេតុក្នុងចំណុចណាមួយខាងលើ សាមីជនត្រូវដោះស្រាយចំពោះមុខច្បាប់ជាធរមាន។

គ- ការហាមឃាត់ការស្នាក់នៅបណ្តោះអាសន្ន

១-លិខិតឆ្លងដែន ឬឯកសារធ្វើដំណើរគ្មានតម្លៃ។

២-គ្មានទិដ្ឋាការចូល លើកលែងតែប្រទេសដែលមានកិច្ចព្រមព្រៀងជាមួយព្រះរាជាណាចក្រកម្ពុជា។

៣-វិកលចរិត។

៤-គ្មានបោះត្រាបញ្ជាក់ការចូលព្រះរាជាណាចក្រកម្ពុជា ពីមន្ត្រីអន្តោប្រវេសន៍កម្ពុជាប្រចាំនៅច្រកទ្វារអន្តរជាតិ ឬច្រកទ្វារទេ្វភាគីណាមួយ។

៥-ខ្វះលទ្ធភាពចិញ្ចឹមខ្លួន និងក្រុមគ្រួសារគ្មានជនណាផ្សេងធានាជួយដោះស្រាយ ។

៦-ក្លែងបន្លំ កោស លុប សរសេរត្រួត ឬបន្ថែមទិន្នន័យនៅលើឯកសារធ្វើដំណើរ ទិដ្ឋាការ បណ្ណស្នាក់នៅ សៀវភៅការងារ ឬឯកសារពាក់ព័ន្ធផ្សេងៗ។

៧-ក្រសួងមហាផ្ទៃពិនិត្យឃើញថា មានអាកប្បកិរិយាធ្វើឲ្យខូចផលប្រយោជន៍សណ្តាប់ធ្នាប់សាធារណៈ សីលធម៌សង្គម និងធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខជាតិ អន្តរជាតិ។

ក្នុងករណីអ្នកស្នើសុំទិដ្ឋាការបន្តរយៈពេលស្នាក់នៅ មានមូលហេតុក្នុងចំណុចណាមួយខាងលើ អាជ្ញាធរមានសមត្ថកិច្ចក្រសួងមហាផ្ទៃ ត្រូវបណ្តេញសាមីជនឲ្យចាកចេញផុតពីព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៤.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អាចលុបចោលឬមិនពន្យារទិដ្ឋាការ ឬមិនអនុញ្ញាតឲ្យស្នាក់នៅបណ្តោះអាសន្នចំពោះមូលហេតុណាមួយដូចខាងក្រោម៖

១-ជនដែលកាន់ទិដ្ឋាការអាចបង្កឲ្យមានគ្រោះថ្នាក់ដល់សន្តិសុខជាតិ។

២-ទិដ្ឋាការដែលបានមកដោយការក្លែងបន្លំ ឬកោសលុប។

៣-ជនដែលកាន់ទិដ្ឋាការបានរំលោភលើបទប្បញ្ញត្តិ ឬច្បាប់នានានៃព្រះរាជាណាចក្រកម្ពុជា។

៤-ជនដែលកាន់ទិដ្ឋាការត្រូវបានកាត់ទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**មាត្រា២៥.-**

ជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលស្នាក់នៅហួសរយៈពេលកំណត់ក្រោម៣០(សាមសិប)ថ្ងៃ ត្រូវបង្ខំឲ្យបង់ប្រាក់ពិន័យអន្តរការណ៍ ១០(ដប់)ដុល្លារអាម៉េរិកក្នុងមួយថ្ងៃ ដែលអនុវត្តដោយអគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ។

**មាត្រា២៦.-**

១-ជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលស្នាក់នៅហួសរយៈពេលកំណត់លើសពី៣០(សាមសិប) ថ្ងៃ ត្រូវបង្ខំឲ្យបង់ប្រាក់ពិន័យអន្តរការណ៍ដោយអនុលោមតាមមាត្រា២៥នៃអនុក្រឹត្យនេះ ហើយតម្រូវឲ្យចាកចេញផុតពីព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល០៧(ប្រាំពីរ)ថ្ងៃយ៉ាងយូរ។

២-ក្នុងករណីរឹងរូស ឬគេចវេះ មិនចាកចេញពីកម្ពុជាតាមការកំណត់ដូចមានចែងក្នុងចំណុចទី១ខាងលើនេះ សាមីជនត្រូវបង្ខំឲ្យបង់ប្រាក់ពិន័យអន្តរការណ៍ទ្វេដង ហើយត្រូវដំណើរការនីតិវិធី និងរៀបចំបែបបទបណ្តេញចេញតាមច្បាប់ស្តីពីអន្តោប្រវេសន៍។

**មាត្រា២៧.-**

១-ជនបរទេសមិនមែនអន្តោប្រវេសន្តដែលមានសកម្មភាពផ្ទាល់ខ្លួនបង្ហាញថាបានប្រើប្រាស់ទិដ្ឋាការខុសពីគោលបំណងដែលបានស្នើសុំ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ស្មើនឹង១០០(មួយរយ)ដុល្លារអាម៉េរិក ហើយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវបញ្ជាឲ្យចាកចេញផុតពីព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល០៧(ប្រាំពីរ) ថ្ងៃយ៉ាងយូរ។

២-ក្នុងករណីរឹងរូស ឬគេចវេះមិនចេញពីកម្ពុជា តាមការកំណត់ដូចមានចែងក្នុងចំណុចទី១ខាងលើនេះ សាមីជនត្រូវបង្ខំឲ្យបង់ប្រាក់ពិន័យអន្តរការណ៍ទ្វេដង ហើយត្រូវដំណើរការនីតិវិធី និងរៀបចំបែបបទបណ្តេញចេញតាមច្បាប់ស្តីពីអន្តោប្រវេសន៍។

**មាត្រា២៨.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានសិទ្ធិលើកលែងការពិន័យដូចមានចែងក្នុងមាត្រា២៥ មាត្រា២៦ និង មាត្រា២៧ នៃអនុក្រឹត្យនេះ។

**មាត្រា២៩.-**

ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឲ្យរលត់បណ្តឹងអាជ្ញា។

ក្នុងករណីមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ សំណុំរឿងនៃបទល្មើសត្រូវបញ្ជូនទៅតុលាការតាមនីតិវិធី លើកលែងការអនុវត្តមាត្រា២៨ ខាងលើនេះ។

ប្រាក់ពិន័យអន្តរការណ៍ត្រូវបង់ចូលថវិកាជាតិ។

បែបបទ និងនីតិវិធីនៃការបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា៣០._**

អនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពី បែបបទសំរាប់អនុវត្តចំពោះការអនុញ្ញាតអោយជនបរទេសមិនមែនអន្តោប្រវេសន្ត ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៣១._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីគោរពជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី សូមហត្ថលេខា**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៦២៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

### សម្រេច

**មាត្រា ១**.-បំពាក់ **មេដាយការងារ** ជូនមន្ត្រីរាជការចំនួន ២២រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសការងារ**

| | | |
|---|---|---|
| ១-លោក | សន ស៊ីណា | មន្ត្រីរាជការ |
| ២-លោក | សួស តារារ័ត្ន | មន្ត្រីរាជការ |
| ៣-លោក | សាន សុផាន់ណា | មន្ត្រីរាជការ |
| ៤-លោកស្រី | ហួត សុវណ្ណនារី | មន្ត្រីរាជការ |
| ៥-លោក | អន សារាដេត | មន្ត្រីរាជការ |
| ៦-លោក | សុខ ណារុំ | មន្ត្រីរាជការ |
| ៧-លោក | អ៊ាង ណាត | មន្ត្រីរាជការ |
| ៨-លោក | អៀង សុមនា | មន្ត្រីរាជការ |
| ៩-លោក | ប៊ុច ស៊ីថន | មន្ត្រីរាជការ |
| ១០-លោក | សាន់ វិសាល | មន្ត្រីរាជការ |
| ១១-លោក | ប៉ែន សន្តិភាព | មន្ត្រីរាជការ |

**ខ-មេដាយប្រាក់ការងារ**

| | | |
|---|---|---|
| ១ លោក | វង្ស ម៉ានិត | មន្ត្រីរាជការ |

| | | |
|---|---|---|
| ២-លោក | ស៊ីង ប៉ូលីន | មន្ត្រីរាជការ |
| ៣-លោក | ណៃ សុផុន | មន្ត្រីរាជការ |
| ៤-លោក | ឆែម ណាងសុង | មន្ត្រីរាជការ |
| ៥-លោក | ប៉ោ សុខណាក់ | មន្ត្រីរាជការ |
| ៦-លោក | សំអៀន សិទ្ធិយុត្តិ | មន្ត្រីរាជការ |
| ៧-លោក | តូច វុឌ្ឍី | មន្ត្រីរាជការ |

**គ-មេធាវីសំរឹទ្ធភារធារ**

| | | |
|---|---|---|
| ១-លោក | ឌុក ផុន | មន្ត្រីរាជការ |
| ២-លោកស្រី | លឹម ណារី | មន្ត្រីរាជការ |
| ៣-លោក | ត្រឹង រដ្ឋា | មន្ត្រីរាជការ |
| ៤-លោក | ហាក់ ផានិត | មន្ត្រីរាជការ |

**មាត្រា ២**.-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៦៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីកាបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

**មាត្រា១**-.ប្រគេនមេដាយចំពោះព្រះសង្ឃ និងបំពាក់មេដាយជូនសប្បុរសជនដែលមានស្នាដៃ និងគុណបំណាច់ក្នុងការចូលរួមចំណែកកសាងសមិទ្ធផល និងអភិវឌ្ឍន៍លើគ្រប់វិស័យក្នុងស្រុករុក្ខគីរី ខេត្តបាត់ដំបង ដូចខាងក្រោមៈ

**ក-មេដាយមុន្នីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទៈ**

| | | | |
|---|---|---|---|
| ១- | លោក | **ផេង ផល** | នាយករដ្ឋបាលសាលាស្រុករុក្ខគីរី |
| ២- | លោក | **ហ៊ុយ គឹមណា** | សប្បុរសជន |
| ៣- | លោក | **ជឹម គុងបេង** | សប្បុរសជន |
| ៤- | លោក | **ស៊ូ អមរិន្ទ** | សប្បុរសជន |
| ៥- | លោកស្រី | **ទ្រឿង វណ្ណានី** | សប្បុរសជន |
| ៦- | លោកស្រី | **ជិន ម៉ិច** | សប្បុរសជន |
| ៧- | លោកស្រី | **ជឹម សុវណ្ណាឡូរី** | សប្បុរសជន |
| ៨- | លោកស្រី | **ជឹម ហៅឡេង** | សប្បុរសជន |

| | | | |
|---|---|---|---|
| ៩- | លោក | **ជីម វ៉ូប៊ីត** | សប្បុរសជន |
| ១០- | លោក | **ជីម ត្រីស្តូព័រ** | សប្បុរសជន |
| ១១- | លោក | **ស៊ូ អមរារិទ្ធិវណ្ណា** | សប្បុរសជន |
| ១២- | លោក | **ស៊ូ ពង្សរតនៈ** | សប្បុរសជន |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា:**

| | | | |
|---|---|---|---|
| ១- | លោកស្រី | **ច្រឹក ពៅដា** | សមាជិកក្រុមប្រឹក្សាស្រុកវុឌ្ឍគីរី |
| ២- | លោក | **ឆន គឹមឈុន** | សមាជិកក្រុមប្រឹក្សាស្រុកវុឌ្ឍគីរី |
| ៣- | លោក | **រួន អែល** | សមាជិកក្រុមប្រឹក្សាស្រុកវុឌ្ឍគីរី |
| ៤- | លោក | **សួន ពឿន** | សមាជិកក្រុមប្រឹក្សាស្រុកវុឌ្ឍគីរី |
| ៥- | លោក | **គ្រឿម រដ្ឋា** | អភិបាលរងនៃគណៈអភិបាលស្រុកវុឌ្ឍគីរ |
| ៦- | លោក | **អ៊ូច សម្បត្តិ** | មេឃុំមុខរាហ៍ ស្រុកវុឌ្ឍគីរី |
| ៧- | លោក | **ស៊ា ស៊ី** | មេឃុំបាសាក់ ស្រុកវុឌ្ឍគីរី |
| ៨- | លោក | **អ៊ូ អៀង** | មេឃុំស្តុកប្រវឹក ស្រុកវុឌ្ឍគីរី |
| ៩- | លោក | **តិន ផុន** | មេឃុំព្រៃត្រឡាច ស្រុកវុឌ្ឍគីរី |
| ១០- | លោក | **អោម សែម** | មេឃុំព្រែកជីក ស្រុកវុឌ្ឍគីរី |
| ១១- | លោក | **ឈិត សំអាត** | នាយករងរដ្ឋបាលសាលាស្រុកវុឌ្ឍគីរី |

**គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ:**

| | | | |
|---|---|---|---|
| ១- | ព្រះតេជគុណ | **ឃុន ចាន់សុឃី** | ចៅអធិការវត្តកំរ៉ែង ស្រុកវុឌ្ឍគីរី |
| ២- | ព្រះតេជគុណ | **ឃឹម ម៊ិន** | ចៅអធិការវត្តបាសាក់ ស្រុកវុឌ្ឍគីរី |
| ៣- | ព្រះតេជគុណ | **ឌុច ខយ** | ចៅអធិការវត្តទេពវង្សី ស្រុកវុឌ្ឍគីរី |

**ឃ-មេដាយការងារ ថ្នាក់ មាស:**

| | | | |
|---|---|---|---|
| ១- | ព្រះតេជគុណ | **មួន ហៃ** | គង់នៅវត្តទេពវង្សី ស្រុកវុឌ្ឍគីរី |
| ២- | លោក | **ឡាក់ វណ្ណា** | មន្ត្រីសាលាស្រុកវុឌ្ឍគីរី |
| ៣- | លោក | **រ៉ឹត ឆារ៉ា** | មន្ត្រីសាលាស្រុកវុឌ្ឍគីរី |
| ៤- | លោកស្រី | **អៀង សុភឿន** | មន្ត្រីសាលាស្រុកវុឌ្ឍគីរី |
| ៥- | លោក | **ភេន សុខាន់** | មន្ត្រីសាលាស្រុកវុឌ្ឍគីរី |
| ៦- | លោក | **ឈើត សុខលី** | មន្ត្រីសាលាស្រុកវុឌ្ឍគីរី |
| ៧- | លោក | **ថៃ ដាវិន** | មន្ត្រីសាលាស្រុកវុឌ្ឍគីរី |
| ៨- | លោក | **គីម រ៉ា** | មន្ត្រីសាលាស្រុកវុឌ្ឍគីរី |
| ៩- | លោក | **ពេជ្រ សំអុល** | សប្បុរសជន |
| ១០- | លោក | **យ៉ែម ពុទ្ធារី** | សប្បុរសជន |

| | | | |
|---|---|---|---|
| ១១- | លោក | **ជិន សាធ** | សប្បុរសជន |
| ១២- | លោក | **ជិន សុធា** | សប្បុរសជន |
| ១៣- | លោក | **ជិន សុគា** | សប្បុរសជន |
| ១៤- | លោក | **ចាប ម៉ាលី** | សប្បុរសជន |
| ១៥- | លោក | **ឯក ឆេង** | សប្បុរសជន |
| ១៦- | លោក | **ថែម សុន** | សប្បុរសជន |
| ១៧- | លោក | **ឃុយ នន** | សប្បុរសជន |
| ១៨- | លោក | **ហួត សំប៊ុន** | សប្បុរសជន |
| ១៩- | លោក | **នៅ ប៊ុនធីម** | សប្បុរសជន |
| ២០- | លោក | **សួន នាម** | សប្បុរសជន |
| ២១- | លោក | **ស៊ឹង ម៉ៃ** | សប្បុរសជន |
| ២២- | លោក | **ម៉ៅ ម៉ុន** | សប្បុរសជន |
| ២៣- | លោក | **ប្រាក់ សុខ** | សប្បុរសជន |
| ២៤- | លោក | **ណែម ណឹម** | សប្បុរសជន |
| ២៥- | លោក | **ជា ចាន់** | សប្បុរសជន |
| ២៦- | លោកស្រី | **ប៉ាល់ ម៉េត** | សប្បុរសជន |
| ២៧- | លោក | **សោម ហេង** | សប្បុរសជន |
| ២៨- | លោក | **អ៊ិន ហួន** | សប្បុរសជន |
| ២៩- | លោក | **អេង ម៉ិន** | សប្បុរសជន |
| ៣០- | លោក | **ហ៊ុន ខែត** | សប្បុរសជន |
| ៣១- | លោក | **ជី ជឹម** | សប្បុរសជន |
| ៣២- | ឧបាសិកា | **ញ៉ៀម សៃ** | សប្បុរសជន |

**ខ-មេធាយការខារ ថ្នាក់ សំរិទ្ធ:**

| | | | |
|---|---|---|---|
| ១- | លោក | **តា សន** | សប្បុរសជន |
| ២- | ឧបាសិកា | **សុខ ចាន់** | សប្បុរសជន |
| ៣- | លោក | **សុត្រា សាន** | សប្បុរសជន |
| ៤- | លោក | **ជា គីម** | សប្បុរសជន |
| ៥- | លោក | **នាង ឡឿន** | សប្បុរសជន |
| ៦- | លោក | **អ៊ិន សារឿន** | សប្បុរសជន |

| | | | |
|---|---|---|---|
| ៧- | លោក | **តាប់ តុល** | សប្បុរសជន |
| ៨- | លោក | **ឡួន ណៃម** | សប្បុរសជន |
| ៩- | លោក | **ឈិន ឈឹម** | សប្បុរសជន |

**មាត្រា ២**.-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦២៦ អនក្រ-បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីកាបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១-.** ប្រគេនមេដាយចំពោះព្រះសង្ឃ និងបំពាក់មេដាយជូនសប្បុរសជនដែលមានស្នាដៃក្នុងការចូលរួមចំណែកកសាងសមិទ្ធផលនានាក្នុង**វត្តខន្តីអេងឈាសទ្ធារាម** ស្ថិតក្នុងឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង ដូចខាងក្រោមៈ

**ក- មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:**

| | | | |
|---|---|---|---|
| ១- | ព្រះតេជគុណ | **ទុយ លីហួច** | ចៅអធិការវត្តខន្តីអេងឈាសទ្ធារាម |
| ២- | លោក | **ផន ឈា** | សប្បុរសជន |
| ៣- | លោកស្រី | **តាំង គីមអេង** | សប្បុរសជន |
| ៤- | លោកស្រី | **ជាង យឿន** | សប្បុរសជន |
| ៥- | លោក | **សូ ស៊ីស** | សប្បុរសជន |

**ខ- មេដាយការងារ ថ្នាក់ មាស:**

| | | | |
|---|---|---|---|
| ១- | លោក | **លឹម ប៉េងជីវ** | សប្បុរសជន |
| ២- | លោក | **ចឹក ថន** | សប្បុរសជន |
| ៣- | លោក | **ហាន្យ ហ៊ុយ** | សប្បុរសជន |

| | | | |
|---|---|---|---|
| ៤- | លោក | **ម៉ាក់ ឆេង** | សប្បុរសជន |
| ៥- | លោក | **ម៉ិច សុគុណា** | សប្បុរសជន |
| ៦- | លោក | **ឡេង ឆឿន** | សប្បុរសជន |
| ៧- | លោក | **ឈាង ស៊ីចហេង** | សប្បុរសជន |
| ៨- | លោក | **ឆាន់ ចាំង** | សប្បុរសជន |
| ៩- | លោក | **ឆេង ស្រេង** | សប្បុរសជន |
| ១០- | លោក | **យី ប៊ុនសុង** | សប្បុរសជន |
| ១១- | លោក | **សុខ រីន** | សប្បុរសជន |
| ១២- | លោក | **សូ សុខ** | សប្បុរសជន |
| ១៣- | លោក | **លី ប៊ុនរ័ត្ន** | សប្បុរសជន |
| ១៤- | លោក | **ទិន ឆួយ** | សប្បុរសជន |
| ១៥- | លោកស្រី | **អ៊ឹម សានិត** | សប្បុរសជន |
| ១៦- | លោកស្រី | **ភាំង ប៉ោឆាង** | សប្បុរសជន |
| ១៧- | លោកស្រី | **តាំង អៀងស៊ុយ** | សប្បុរសជន |
| ១៨- | លោកស្រី | **ផុន ផល្លី** | សប្បុរសជន |
| ១៩- | លោកស្រី | **ហុក ជួន** | សប្បុរសជន |
| ២០- | លោកស្រី | **ខឹម តាន់** | សប្បុរសជន |
| ២១- | លោកស្រី | **ឈុន យ៉ាត** | សប្បុរសជន |

**មាត្រា ២**-.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៧៣ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យច្បាប់ប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា ១** : តែងតាំងមន្ត្រីរាជការចំនួន ០៣រូប នៃក្រសួងពាណិជ្ជកម្ម ដូចខាងក្រោម ៖

១-លោក **ចៅ សុខមុនី** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ ជំនួសលោក **សួន ភារិទ្ធ** ដែលត្រូវបានទៅទទួលភារកិច្ចថ្មី

២-លោកស្រី **អ៊ឹង វណ្ណារី** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ជំនួសលោក **រតន៍ សាម៉ន** ដែលត្រូវបានទៅទទួលភារកិច្ចថ្មី

៣-លោក **គីម ច័ន្ទរស្មី** ជាប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ជំនួសលោក **អ៊ូ សុផល** ដែលត្រូវបានទៅទទួលភារកិច្ចថ្មី។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យសម្តេច ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា៣*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៧២៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .–**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ផ្តល់ជូនសប្បុរសជនចំនួន ០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ ដងទង់ ០១គូ និងសមិទ្ធផលនានាជាច្រើនទៀត នៅ**វត្តថ្មកែវ** ស្ថិតនៅក្នុងឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានរាយនាមដូចខាងក្រោម :

| | | |
|---|---|---|
| ១-សីលវតី **ឈុន គឹមស្រៀង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៥០.០០០ ដុល្លារ |
| ២-លោក **គង់ ផល្លា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៤៩.០០០ ដុល្លារ |
| ៣-លោក **គង់ ម៉ារ៉ឌី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៤៨.០០០ ដុល្លារ |

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៧៤ អនក្រ.បក

## អនុក្រឹត្យ
### ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

មាត្រា ១.–

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ១២ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ ដងទង់ ០១គូ និងសមិទ្ធផលនានាជាច្រើនទៀត នៅ***វត្តថ្មកែវ*** ស្ថិតនៅក្នុងឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **លឹម នុន** | ព្រះចៅអធិការវត្តថ្មកែវ | បច្ច័យចំនួន ១០.០០០ ដុល្លារ |
| ២-ឧបាសិកា | **តាំង ណៃអ៊ីម** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៣-លោកស្រី | **សោម ពៅ** | សប្បុរសជននៅខេត្តតាកែវ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៤-ឧបាសិកា | **ថៅ សាគុំ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៥-លោក | **ទៀង សេដ្ឋា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៦-លោកស្រី | **គង់ គីមហៀន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៧-ឧបាសក | **អ៊ុយ បូរ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៨-ឧបាសិកា | **ហោ យ៉ិនឡាំង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០០០ ដុល្លារ |

| | | | |
|---|---|---|---|
| ៩-លោកស្រី | **ឆែ សុខឃីម** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ១០-លោក | **ពេជ សំណាង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ១១-ឧបាសក | **សោម ហេន** | សប្បុរសជននៅខេត្តតាកែវ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ១២-លោក | **ណុប ធី** | សប្បុរសជននៅខេត្តតាកែវ | ថវិកាចំនួន ១០.០០០ ដុល្លារ |

មាត្រា ២ . —

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ  រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ  រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ  ហ៊ុន  សែន**

**<u>កន្លែងទទួល</u>** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ  កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៣០ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- អនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមុខងារសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា ១-** តែងតាំងលោក **សុខ សេងយ៉ន** ជានាយករងសាលាភូមិន្ទរដ្ឋបាល មានឋានៈស្មើអគ្គនាយករងរបស់ក្រសួងមុខងារសាធារណៈ ជំនួសលោក វ៉ាន់ ប៉ូលុយ ដែលបានចូលនិវត្តន៍។

**មាត្រា ២-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*<u>កន្លែងទទួល</u>*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **ស៊ិន សុខាបុត្ត** អត្តលេខ ៥៧៣៥១ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៦៣៧...អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយការងារ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា ១.**-បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ៤៥រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច បម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសការងារ**

| | | |
|---|---|---|
| ១- | លោក **ឡាំង ថន** | អនុប្រធាននាយកដ្ឋាន |
| ២- | លោក **នុត សចូះ** | អនុប្រធាននាយកដ្ឋាន |
| ៣- | លោកស្រី **គង់ សុមនី** | អនុប្រធាននាយកដ្ឋាន |
| ៤- | លោក **អេម សំបូរ** | ប្រធានការិយាល័យ |
| ៥- | លោក **ឡោ សុវណ្ណី** | ប្រធានការិយាល័យ |
| ៦- | លោកស្រី **អ៊ួន សុខចំន្ទ** | ប្រធានការិយាល័យ |
| ៧- | លោកស្រី **ហុន្ស ម៉ាស៊ីវត្ថា** | ប្រធានការិយាល័យ |
| ៨- | លោក **សេង សារ៉េន** | ប្រធានការិយាល័យ |
| ៩- | លោក **ស្រេង ហៃសេង** | ប្រធានការិយាល័យ |
| ១០- | លោក **ភាំង ស្រ៊ី** | ប្រធានការិយាល័យ |
| ១១- | លោក **ហាក់ យ៉ាង** | ប្រធានការិយាល័យ |
| ១២- | លោកស្រី **ស៊ិន សុមេធា** | ប្រធានការិយាល័យ |
| ១៣- | លោកស្រី **យស ចិន្តាមុន្នី** | ប្រធានការិយាល័យ |
| ១៤- | លោកស្រី **ពេជ្រ បូរ៉ានី** | អនុប្រធានការិយាល័យ |
| ១៥- | លោកស្រី **លាប ចំន្ទធីតា** | អនុប្រធានការិយាល័យ |
| ១៦- | លោក **ចំរើន ថាវុធ** | អនុប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី៩ |
| ១៧- | លោក **មុន្នី ចំន្ទវណ្ណះ** | អនុប្រធានការិយាល័យ |

ខ-មេដាយប្រាក់ការងារ

| | | |
|---|---|---|
| ១- | លោកស្រី **សាយ បុញ្ញវតី** | នាយិការងខុទ្ទកាល័យ |
| ២- | លោក **មាស តូនី** | អនុប្រធាននាយកដ្ឋាន |
| ៣- | លោកស្រី **សួស សុគន្ធា** | ប្រធានការិយាល័យ |
| ៤- | លោកស្រី **ប៉ូ សុពណ៌** | ប្រធានការិយាល័យ |
| ៥- | លោក **នោម សំអឿន** | ប្រធានការិយាល័យ |
| ៦- | លោក **ឌូច ឧត្តម** | ប្រធានលេខាធិការដ្ឋានភូមិភាគទី៥ |
| ៧- | លោក **ហម ម៉ាលីដា** | ប្រធានលេខាធិការដ្ឋានភូមិភាគទី៧ |
| ៨- | លោកស្រី **សឿន រតនា** | អនុប្រធានការិយាល័យ |
| ៩- | លោក **មាស សទ្វារ** | អនុប្រធានការិយាល័យ |
| ១០- | លោកស្រី **សុខ លក្ខលីដា** | អនុប្រធានការិយាល័យ |
| ១១- | លោក **សុខ ពិសាល** | អនុប្រធានការិយាល័យ |
| ១២- | លោក **យ៉ុង សុធា** | អនុប្រធានការិយាល័យ |
| ១៣- | លោក **ណឹប សុគន្ធី** | អនុប្រធានការិយាល័យ |
| ១៤- | លោក **អ៊ុក ឌុំ** | អនុប្រធានការិយាល័យ |
| ១៥- | លោក **ដាន់ មករា** | អនុប្រធានការិយាល័យ |
| ១៦- | លោក **ឡុង សុទិដ្ឋត្សា** | អនុប្រធានការិយាល័យ |
| ១៧- | លោកស្រី **អ៊ែល កញ្ញា** | អនុប្រធានការិយាល័យ |
| ១៨- | លោក **គីម ភារុន** | អនុប្រធានការិយាល័យ |
| ១៩- | លោក **ញ៉ៀម សីហា** | អនុប្រធានការិយាល័យ |
| ២០- | លោក **នួន ស៊ីថា** | អនុប្រធានការិយាល័យ |
| ២១- | លោក **ស៊ូ ថុល** | អនុប្រធានលេខាធិការដ្ឋានភូមិភាគទី៥ |
| ២២- | លោកស្រី **កែ ស៊ីណេត** | ប្រធានផ្នែក |
| ២៣- | លោក **ឌូច សារឿន** | ប្រធានផ្នែក |
| ២៤- | លោក **ហួត សុភ័ត្រា** | មន្ត្រីលេខាធិការដ្ឋានអមគណៈកម្មការទី៤ |
| ២៥- | លោកស្រី **ជី សុភា** | មន្ត្រីលេខាធិការដ្ឋានអមគណៈកម្មការទី៦ |
| ២៦- | លោក **យឹម សោភ័ណ្ឌ** | មន្ត្រីរាជការ |
| ២៧- | លោក **អ៊ាង ណារី** | មន្ត្រីរាជការ |
| ២៨- | លោកស្រី **ឈឹម ធីតា** | មន្ត្រីរាជការ |

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦៨៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

### សម្រេច

**មាត្រា១.**-បំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ ចំនួន ៤ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

-លោក ឡើម ម៉ុនរឿន ប្រធានមន្ទីរមុខងារសាធារណៈ ខេត្តពោធិ៍សាត់

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ**

១-លោក នាក់ ណាង ប្រធានមន្ទីរមុខងារសាធារណៈ ខេត្តប៉ៃលិន

២-លោក សៀង សារិត ប្រធានមន្ទីរមុខងារសាធារណៈ ខេត្តព្រះវិហារ

៣-លោក អ៊ុក ឧត្តម ប្រធានមន្ទីរមុខងារសាធារណៈ ខេត្តឧត្តរមានជ័យ

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៣៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

### សម្រេច

**មាត្រា១.** បំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ ចំនួន ៨៥ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសការងារ**

| | | | |
|---|---|---|---|
| ១-លោក | ហែម | ឌី | អគ្គាធិការរង |
| ២-លោក | ជា | ឡាលីន | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៣-លោកស្រី | ជូ | សុជាតិ | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងសរុប |
| ៤-លោក | ណុប | ពិសិទ្ធ | អនុប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក |
| ៥-លោក | កែវ | សាត់ | អនុប្រធាននាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ៦-លោកស្រី | ឈាង | អូនថា | អនុប្រធាននាយកដ្ឋានសេវាសាធារណៈ |
| ៧-លោក | ខូន | សុកិត្យា | អនុប្រធាននាយកដ្ឋានសេវាសាធារណៈ |
| ៨-លោក | សយ | សុវណ្ណា | អនុប្រធាននាយកដ្ឋានគោលនយោបាយលាភការ និងសមិទ្ធកម្ម |
| ៩-លោក | ហួត | វិជ្ជ័យ | អនុប្រធាននាយកដ្ឋានគោលនយោបាយលាភការ និងសមិទ្ធកម្ម |
| ១០-លោក | លន | គីមហេង | អនុប្រធាននាយកដ្ឋានត្រួតពិនិត្យ និងវាយតម្លៃ |
| ១១-លោក | ទើង | សាត | អនុប្រធាននាយកដ្ឋានត្រួតពិនិត្យ និងវាយតម្លៃ |
| ១២-លោក | មាស | សុវ៉ាទី | អនុប្រធាននាយកដ្ឋានត្រួតពិនិត្យ និងវាយតម្លៃ |
| ១៣-លោកស្រី | អ៊ឹម | សុវណ្ណារី | ប្រធានការិយាល័យ |
| ១៤-លោក | សុខ | ម៉ានិត | ប្រធានការិយាល័យ |
| ១៥-លោក | អឿង | មុន្នី | ប្រធានការិយាល័យ |

| | | | |
|---|---|---|---|
| ១៦-លោកស្រី | ឡាយ | លីកា | ប្រធានការិយាល័យ |
| ១៧-លោក | សុខ | វណ្ណា | ប្រធានមន្ទីរមុខងារសាធារណៈ ខេត្តត្បូងឃ្មុំ |
| ១៨-លោក | ពុច | សុរិយា | ប្រធានមន្ទីរមុខងារសាធារណៈ ខេត្តមណ្ឌលគិរី |
| ១៩-លោក | សាន់ | វឌ្ឍនៈ | ប្រធានការិយាល័យ មន្ទីរមុខងារសាធារណៈ ខេត្តព្រះសីហនុ |
| ២០-លោក | សឿង | វណ្ណៈ | ប្រធានការិយាល័យ មន្ទីរមុខងារសាធារណៈ ខេត្តព្រះសីហនុ |
| ២១-លោក | គ្រឹម | ម៉ារ៉ាឌី | អនុប្រធានមន្ទីរមុខងារសាធារណៈ ខេត្តក្រចេះ |
| ២២-លោក | សៀង | ទ៊ាន | អនុប្រធានមន្ទីរមុខងារសាធារណៈ ខេត្តក្រចេះ |
| ២៣-លោកស្រី | សំរិត | សមិទ្ធិ | អនុប្រធានមន្ទីរមុខងារសាធារណៈ ខេត្តព្រៃវែង |
| ២៤-លោក | ឌី | ផល្លា | អនុប្រធានមន្ទីរមុខងារសាធារណៈ ខេត្តមណ្ឌលគិរី |
| ២៥-លោក | ជា | ហាប់ | អនុប្រធានមន្ទីរមុខងារសាធារណៈ ខេត្តបាត់ដំបង |
| ២៦-លោក | ម៉ក់ | សម្បត្តិ | អនុប្រធានមន្ទីរមុខងារសាធារណៈ ខេត្តព្រះវិហារ |
| ២៧-លោកស្រី | អ៊ុន | សុគន្ធីតា | អនុប្រធានមន្ទីរមុខងារសាធារណៈ ខេត្តកោះកុង |
| ២៨-លោក | មាស | ហាក់រស្មី | អនុប្រធានមន្ទីរមុខងារសាធារណៈ ខេត្តរតនគិរី |
| ២៩-លោកស្រី | ជា | សារឿន | ប្រធានការិយាល័យ មន្ទីរមុខងារសាធារណៈ ខេត្តកំពង់ធំ |

ខ-មេដាយប្រាក់ការងារ

| | | | |
|---|---|---|---|
| ១-លោក | អ៊ុច | សារ៉ាវ៉ាន់ | ប្រធាននាយកដ្ឋានស្រាវជ្រាវ និងទំនាក់ទំនងអន្តរជាតិ |
| ២-លោក | ជា | ចំរុង | ប្រធានអង្គភាពលទ្ធកម្ម |
| ៣-លោកស្រី | សេង | សេរីវឌ្ឍនា | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៤-លោក | ម៉ែន | ចាន់ថន | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងសរុប |
| ៥-លោក | គីម | ដាលី | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងសរុប |
| ៦-លោក | គង់ | អភិវឌ្ឍន៍ | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងស្ថាប័ន |
| ៧-លោក | សួន | សុវណ្ណា | អនុប្រធាននាយកដ្ឋានត្រួតពិនិត្យនិងវាយតម្លៃ |
| ៨-លោក | ញៀម | វិទ្ធិកា | អនុប្រធាននាយកដ្ឋានស្រាវជ្រាវ និងទំនាក់ទំនងអន្តរជាតិ |
| ៩-លោក | សរ | បូរ៉ា | អនុប្រធាននាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ១០-លោក | អេង | សេតសុតា | អនុប្រធាននាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ១១-លោកស្រី | គីត | គុស្សនា | អនុប្រធាននាយកដ្ឋាននីតិកម្ម និងវិវាទមុខងារសាធារណៈ |
| ១២-លោក | ទ័រ | សុផល | អនុប្រធាននាយកដ្ឋានគ្រប់គ្រងក្របខ័ណ្ឌ |
| ១៣-លោក | មាស | សម្ផស្ស | អនុប្រធាននាយកដ្ឋានគ្រប់គ្រងក្របខ័ណ្ឌ |
| ១៤-លោកស្រី | ប៉ុក | វិចិត្រតារា | ប្រធានការិយាល័យ |
| ១៥-លោក | សៀង | សម្បត្តិ | ប្រធានការិយាល័យ |
| ១៦-លោកស្រី | ឯក | ច័ន្ទដានី | អនុប្រធានការិយាល័យ |
| ១៧-លោកស្រី | ឡឿន | ច័ន្ទតុលា | ប្រធានការិយាល័យ |
| ១៨-លោកស្រី | សូត្រ | ចរិយា | ប្រធានការិយាល័យ |
| ១៩-លោក | ឡៅ | សៅរិទ្ធ | មន្ត្រី |
| ២០-លោក | ស៊ូ | សុផល | មន្ត្រី |
| ២១-លោក | ពុត | សុផល | អនុប្រធានមន្ទីរមុខងារសាធារណៈ ខេត្តស្វាយរៀង |
| ២២-លោក | ជា | ឈុននឿន | អនុប្រធានមន្ទីរមុខងារសាធារណៈ ខេត្តឧត្តរមានជ័យ |
| ២៣-លោកស្រី | ទេព | សុវណ្ណចំនួរ័ត្ន | ប្រធានការិយាល័យ មន្ទីរមុខងារសាធារណៈ ខេត្តស្វាយរៀង |
| ២៤-លោក | យ៉េង | សុគំណូ | ប្រធានការិយាល័យ មន្ទីរមុខងារសាធារណៈ ខេត្តព្រៃវែង |
| ២៥-លោក | រិន | សេង | ប្រធានការិយាល័យ មន្ទីរមុខងារសាធារណៈ ខេត្តប៉ៃលិន |

| | | | |
|---|---|---|---|
| ២៦-លោក | ស៊ឹម | រស្មី | ប្រធានការិយាល័យ មន្ទីរមុខងារសាធារណៈ ខេត្តបាត់ដំបង |
| ២៧-លោក | គួច | ស៊ីលា | ប្រធានការិយាល័យ មន្ទីរមុខងារសាធារណៈ ខេត្តបាត់ដំបង |
| ២៨-លោក | ទ្រាក់ | គា | ប្រធានការិយាល័យ មន្ទីរមុខងារសាធារណៈ ខេត្តកោះកុង |
| ២៩-លោក | ហែម | សុគាន់ | ប្រធានការិយាល័យ មន្ទីរមុខងារសាធារណៈ ខេត្តកំពង់ធំ |
| ៣០-លោក | សេង | វឌ្ឍនា | ប្រធានការិយាល័យ មន្ទីរមុខងារសាធារណៈ ខេត្តរតនគិរី |
| ៣១-លោក | ម៉ុន | ឫទ្ធី | ប្រធានការិយាល័យ មន្ទីរមុខងារសាធារណៈ ខេត្តរតនគិរី |
| ៣២-លោកស្រី | ច្រួច | គឹមហ៊ិច | អនុប្រធានការិយាល័យ មន្ទីរមុខងារសាធារណៈ ខេត្តព្រៃវែង |

**គ-មេដាយសំរិទ្ធការងារ**

| | | | |
|---|---|---|---|
| ១-លោក | ហួត | វិច្ឆ័យ | អនុប្រធាននាយកដ្ឋានគោលនយោបាយលាភការ និងសមិទ្ធកម្ម |
| ២-លោក | សុខ | សំណាង | អនុប្រធាននាយកដ្ឋានសម្របសម្រួលការកែទម្រង់អន្តរវិស័យ |
| ៣-លោក | ទ្រាំ | វណ្ណៈ | អនុប្រធាននាយកដ្ឋាននីតិកម្ម និងវិវាទមុខងារសាធារណៈ |
| ៤-លោក | ស | សុវណ្ណា | ប្រធានការិយាល័យ |
| ៥-លោក | ជុំ | ចៅចិត្រ | ប្រធានការិយាល័យ |
| ៦-លោក | ចាន់ | ស៊ីមន្ថា | ប្រធានការិយាល័យ |
| ៧-លោកស្រី | អ៊ីវ | សុជាតា | ប្រធានការិយាល័យ |
| ៨-លោក | ស៊ីន | សេរីវឌ្ឍនា | ប្រធានការិយាល័យ |
| ៩-លោកស្រី | ម៉ៅ | ចិន្តា | ប្រធានការិយាល័យ |
| ១០-លោក | ឈឹន | សាលីន | ប្រធានការិយាល័យ |
| ១១-លោកស្រី | ណុប | សុធារ៉ែន | ប្រធានការិយាល័យ |
| ១២-លោកស្រី | អ៊ិត | ផល្លីស | ប្រធានការិយាល័យ |
| ១៣-លោកស្រី | ឈុន | ពុទ្ធានី | ប្រធានការិយាល័យ |
| ១៤-លោក | ឡេង | សុភក្ត្រ | ប្រធានការិយាល័យ |
| ១៥-លោក | ស៊ុក | សុវណ្ណជា | ប្រធានការិយាល័យ |
| ១៦-លោកស្រី | ជួន | ចំន្ទវុឌ្ឍានី | ប្រធានការិយាល័យ |
| ១៧-លោក | ម៉ុក | ប៊ុណ្ណាវី | ប្រធានការិយាល័យ |
| ១៨-លោក | ម៉ុន | វ៉ាន់ថា | អនុប្រធានការិយាល័យ |
| ១៩-លោកស្រី | សែម | ដានី | អនុប្រធានការិយាល័យ |
| ២០-លោក | ឃឹម | ម៉ុនលីន | អនុប្រធានការិយាល័យ |
| ២១-លោក | ប៊ូល | អម្រិតភិត្យា | មន្ត្រីថ្នាក់កណ្ដាល |
| ២២-លោក | សយ | សុខុន | មន្ត្រីថ្នាក់កណ្ដាល |
| ២៣-លោកស្រី | ពៅ | សុផាន់នី | អនុប្រធានការិយាល័យ មន្ទីរមុខងារសាធារណៈ ខេត្តកោះកុង |
| ២៤-លោកស្រី | សៀន | ទូចលៀង | មន្ត្រី មន្ទីរមុខងារសាធារណៈ ខេត្តត្បូងឃ្មុំ |

**មាត្រា២**.-រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៣៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.**_បំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកជំទាវ **យឹម សុខា ម៉ម សុផាត** ដែលបានផ្តល់ថវិកាចំនួន ៥២.២១៩ ដុល្លារអាមេរិក ក្នុងការសាងសង់អគារសិក្សាថ្មី ចំនួន០១ខ្នង មាន០៥បន្ទប់ ជូនដល់សាលាបឋមសិក្សា **ប៊ុន រ៉ានី ហ៊ុន សែន** ជីភូ ស្ថិតនៅភូមិទួលអំពិល សង្កាត់ច្រកម្ទេស ក្រុងបាវិត ខេត្តស្វាយរៀង ។

**មាត្រា២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦៣៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ

## សម្រេច

**មាត្រា១.**.បំពាក់ **មេដាយសុវត្ថារ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន១០រូប ដែលមានស្នាដៃល្អក្នុងការជួយចុះបំពេញការងារនៅទីតាំងបាញ់គ្រាប់ពិតរបស់កងពល នៅចំណុចវាលចំបក់ ស្រុកជុំគីរី ខេត្តកំពត ព្រមទាំងបានជួយឧបត្ថម្ភជាសម្ភារ បរិក្ខារ និងថវិកាក្នុងការសាងសង់កងពលតូចថ្មើជើងលេខ៧០ នាពេលកន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយ សុវត្ថារា ថ្នាក់ ធិបឌិន្ទ**

១-លោក **ឃាង ម៉េងលាង** សប្បុរសជន

២-លោក **កង ចាន់ថន** សប្បុរសជន

៣-លោក **ជុំ ឧត្តម** សប្បុរសជន

៤-លោក **យ៉ឹក ឃីហ៊ង** សប្បុរសជន

**ខ-មេដាយ សុវត្ថារា ថ្នាក់ សេនា**

១-លោក **ទូច សុផល្លា** សប្បុរសជន

២-លោក **សរ ចចិត្រ** សប្បុរសជន

៣-លោក **ឈ្លាង ប៊ុយ** សប្បុរសជន

៤-លោក **ទឹម ឧដ្ឋារី** សប្បុរសជន

**គ-មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ**

១-លោក **ឥម គុនតូនី** សប្បុរសជន

២-លោក **នាង សុខ** សប្បុរសជន

៣-លោក **គុណា ឧុត្តី** សប្បុរសជន
៤-លោក **សូ សុន** សប្បុរសជន

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អភិបាលនៃគណៈអភិបាលខេត្តកំពត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០១៦
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៦៣៧..អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ

**សម្រេច**

**មាត្រា១.**.បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ សេនា ជូនក្រុមការងារខេត្តកំពត ចំនួន៣រូប ដែលមានស្នាដៃល្អក្នុងការជួយចុះបំពេញការងារនៅទីតាំងបាញ់គ្រាប់ពិតរបស់កងពល នៅចំណុចវាលចិបក់ ស្រុកជុំគីរី ខេត្តកំពត ព្រមទាំងបានជួយឧបត្ថម្ភ ជាសម្ភារ បរិក្ខារ និងថវិកាក្នុងការសាងសង់កងពលតូចថ្មើរជើងលេខ៧០ នាពេលកន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-វរសេនីយ៍ត្រី **ចិន សុគន្ធរ៉ា** នាយរងការិយាល័យហ្វឹកហ្វឺន

២-វរសេនីយ៍ត្រី **ផុន ឈុនហ៊ួ** នាយរងការិយាល័យហ្វឹកហ្វឺន

៣-វរសេនីយ៍ត្រី **ព្រាប បូរិទ្ធ** នាយរងការិយាល័យហ្វឹកហ្វឺន

**មាត្រា២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អភិបាលនៃគណៈអភិបាលខេត្តកំពត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៦៣៨ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ

### សម្រេច

**មាត្រា១.** បំពាក់ **មេដាយមាសការងារ** ជូនក្រុមការងារខេត្តកំពត និងសប្បុរសជន ចំនួន៣៦រូប ដែលមានស្នាដៃល្អក្នុងការជួយចុះបំពេញការងារនៅទីតាំងបាញ់គ្រាប់ពិតរបស់កងពល នៅចំណុចវាលចំបក់ ស្រុកជុំគីរី ខេត្តកំពត ព្រមទាំងបានជួយឧបត្ថម្ភ ជាសម្ភារ បរិក្ខារ និងថវិកាក្នុងការសាងសង់កងពលតូចថ្មើរជើងលេខ៧០ នាពេលកន្លងមក ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ព្រិន្ទបាលទោ | **ឃឹម** | **ភារិន** | មេក្រុម១ កងតូច៣ កងអនុសេនាធំ ៧១១ |
| ២-ព្រិន្ទបាលទោ | **ហ៊ីន** | **សារឿន** | មេក្រុម២ កងតូច៣ កងអនុសេនាធំ ៧១១ |
| ៣-ព្រិន្ទបាលទោ | **ផា** | **ឥមពេជ្រ** | មេក្រុម៣ កងតូច៣ កងអនុសេនាធំ ៧១១ |
| ៤-ព្រិន្ទបាលទោ | **យូ** | **សារិន** | សប្បុរសជន |
| ៥-ព្រិន្ទបាលទោ | **ឈុន** | **អេងតាក់** | សប្បុរសជន |
| ៦-លោក | **យូ** | **ញ៉ាក់** | សប្បុរសជន |
| ៧-លោក | **យូ** | **ប្រុស** | សប្បុរសជន |
| ៨-លោក | **ប៊ូ** | **ស័ក្កដា** | សប្បុរសជន |
| ៩-លោក | **ពិន** | **សាមិត្ត** | សប្បុរសជន |
| ១០-លោក | **ឯម** | **សេដ្ឋា** | អនុប្រធានការិយាល័យ សាលាខេត្តកំពត |
| ១១-លោក | **ព្រំ** | **ចន្ធី** | នាយសង្កាត់ រដ្ឋបាលព្រៃឈើស្រុកជុំគីរី ខេត្តកំពត |

| | | |
|---|---|---|
| ១២-លោក | **ខៀវ គេង** | ក្រុមប្រឹក្សាឃុំ សាលាឃុំតាកែន ខេត្តកំពត |
| ១៣-លោក | **ទុំ គល់** | មេឃុំ សាលាឃុំតាកែន ខេត្តកំពត |
| ១៤-លោក | **ទេព រិទ្ធី** | សប្បុរសជន |
| ១៤-លោក | **គង់ សង្ហា** | សប្បុរសជន |
| ១៥-លោក | **ហោ ខួនឆាយ** | សប្បុរសជន |
| ១៦-លោក | **អ៊ឹង សុវណ្ណារិន** | សប្បុរសជន |
| ១៧-លោក | **អ៊ឹង សុធារ៉ា** | សប្បុរសជន |
| ១៨-លោក | **អ៊ុំ ទិវ៉ាយុទ្ធ** | សប្បុរសជន |
| ១៩-លោក | **ណុប ចន្ធូ** | សប្បុរសជន |
| ២០-លោក | **ឃុន ដូរ៉េ** | សប្បុរសជន |
| ២១-លោក | **ឃុន ដូរ៉ា** | សប្បុរសជន |
| ២២-លោក | **ម៉ី សួសត្យា** | សប្បុរសជន |
| ២៣-លោក | **ចាន់ ណារី** | សប្បុរសជន |
| ២៤-លោក | **ឡឹម ម៉ិនឡុង** | សប្បុរសជន |
| ២៥-លោក | **គង់ សុខខេន** | សប្បុរសជន |
| ២៦-លោក | **ប៉ាង សុខេន** | សប្បុរសជន |
| ២៧-លោក | **ជា ចន្ធី** | សប្បុរសជន |
| ២៨-លោក | **ហ៊ី សុខណាន** | សប្បុរសជន |
| ២៩-លោក | **អៀម ចំរើន** | សប្បុរសជន |
| ៣០-លោក | **ហ៊ិន សំរេន** | សប្បុរសជន |
| ៣១-លោក | **អ៊ិង មករា** | សប្បុរសជន |
| ៣២-លោក | **ប៊ិន កក្កដា** | សប្បុរសជន |
| ៣៣-លោក | **ចិន សុខា** | សប្បុរសជន |
| ៣៤-លោក | **មួង រដ្ឋា** | សប្បុរសជន |
| ៣៥-លោក | **កែន សេរី** | សប្បុរសជន |
| ៣៦-កញ្ញា | **ម៉ន ឥមហ៊ាង** | សប្បុរសជន |

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អភិបាលនៃគណៈអភិបាលខេត្តកំពត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៣៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល កំពង់ផែស្វយ័តក្រុងព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតកំពង់ផែស្វយ័តក្រុងព្រះសីហនុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**មាត្រា ១.-**

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល កំពង់ផែស្វយ័តក្រុងព្រះសីហនុ សម្រាប់អាណត្តិទី៦ ដូចខាងក្រោម៖

| | | |
|---|---|---|
| ១.ឯកឧត្តម **លូ គឹមឈន់** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានអគ្គនាយក | ប្រធាន |
| ២.ឯកឧត្តម **គីមរ៉េត សំរេច** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣.ឯកឧត្តម **ផាន់ ផល្លា** | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤.ឯកឧត្តម **យន្ត មីន** | តំណាងអាជ្ញាធរខេត្តព្រះសីហនុ | សមាជិក |
| ៥.ឯកឧត្តម **ស៊ុយ សាន** | តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៦.ឯកឧត្តម **សុខ សុគ័ន្រ្ធ** | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៥៤...សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៤១៣ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**ប្រការ ១.-**

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (**ក.ជ.អ.ច.**) ដូចខាងក្រោម៖

| | | |
|---|---|---|
| ១-សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** | នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | ប្រធានកិត្តិយស |
| ២-ឯកឧត្តម **សាយ សំអាល់** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ប្រធាន |
| ៣-ឯកឧត្តម **តឹករ៉េត សំរេច** | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | អនុប្រធានទី១ |
| ៤-ឯកឧត្តម **ខៀវ មុត** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | អនុប្រធានទី២ |
| ៥-ឯកឧត្តម **ម៉ម អំណាត់** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៦-ឯកឧត្តម **ឌិត ទីណា** | រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | សមាជិក |
| ៧-ឯកឧត្តម **គន់ ទ៉ាន់ចាវ៉ា** | រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ៨-ឯកឧត្តម **សក់ សេដ្ឋា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៩-ឯកឧត្តម **ឯល ទ៉ាន់សារ៉ាត** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ១០-ឯកឧត្តម **អ៊ុច បូររិទ្ធ** | រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១១-ឯកឧត្តម **ទី តាឃី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១២-ឯកឧត្តម **អ៊ុន ចន្ថា** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៣-ឯកឧត្តម **អ៊ុក ប្រជា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៤-ឯកឧត្តម **សាត សាមី** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ១៥-ឯកឧត្តម **ប៉ាន ប៊ុនធឿន** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១៦-លោកជំទាវ **គឹម សេដ្ឋានី** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៧-ឯកឧត្តម **អះម៉ាត់ យ៉ះយ៉ា** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៨-ឯកឧត្តម **ម៉ែន សុផល** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៩-លោកជំទាវ **ច័ន្ទ ធី** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ២០-លោកជំទាវ **ចាន់ សុទ្ធាវី** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ២១-លោកជំទាវ **សុភ័ក្ត ថាវី** | រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ២២-លោកជំទាវ **ប្រាក់ ច័ន្ទណាយ** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ២៣-ឯកឧត្តម **អ៊ុខ គីរុន** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ២៤-ឯកឧត្តម **តូច ចាន់កុសល** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ២៥-ឯកឧត្តម **ថៃ នរៈសត្យា** | រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ២៦-ឯកឧត្តម **ទិត ចន្ថា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២៧-ឯកឧត្តម **នរៈ រតនវឌ្ឍនោ** | រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា | សមាជិក |
| ២៨-លោកជំទាវ **ស៊ីវណ្ណា បុទុម** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| ២៩-ឯកឧត្តម **ម៉ម វណ្ណៈ** | រដ្ឋលេខាធិការក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | សមាជិក |
| ៣០-ឯកឧត្តម **ម៉ូល ពីឌូ** | រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ៣១-ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** | រដ្ឋលេខាធិការរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |

| | | |
|---|---|---|
| ៣២-ឯកឧត្តម **គីម សុគះ** | អគ្គលេខាធិការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ៣៣-ឯកឧត្តម **សុខ ចិន្តាសោភា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៣៤-ឯកឧត្តម **ខ៉ាន់ ចំរើន** | អនុប្រធានប្រតិបត្តិលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | សមាជិក |
| ៣៥-ឯកឧត្តម **ឡៅ សុខារម្ម** | អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ | សមាជិក |
| ៣៦-ឯកឧត្តម **ម៉ុន ណារិទ្ធិ** | អគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |
| ៣៧-អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ | | សមាជិក |
| ៣៨-អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ | | សមាជិក |
| ៣៩-អភិបាល នៃគណៈអភិបាលខេត្តកែប | | សមាជិក |
| ៤០-អភិបាល នៃគណៈអភិបាលខេត្តប៉ៃលិន | | សមាជិក |
| ៤១-អភិបាល នៃគណៈអភិបាលខេត្តកណ្តាល | | សមាជិក |
| ៤២-អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង | | សមាជិក |
| ៤៣-អភិបាល នៃគណៈអភិបាលខេត្តស្វាយរៀង | | សមាជិក |
| ៤៤-អភិបាល នៃគណៈអភិបាលខេត្តកំពង់ចាម | | សមាជិក |
| ៤៥-អភិបាល នៃគណៈអភិបាលខេត្តតាកែវ | | សមាជិក |
| ៤៦-អភិបាល នៃគណៈអភិបាលខេត្តកំពត | | សមាជិក |
| ៤៧-អភិបាល នៃគណៈអភិបាលខេត្តកោះកុង | | សមាជិក |
| ៤៨-អភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ | | សមាជិក |
| ៤៩-អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ | | សមាជិក |
| ៥០-អភិបាល នៃគណៈអភិបាលខេត្តកំពង់ឆ្នាំង | | សមាជិក |
| ៥១-អភិបាល នៃគណៈអភិបាលខេត្តពោធិ៍សាត់ | | សមាជិក |
| ៥២-អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង | | សមាជិក |
| ៥៣-អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ | | សមាជិក |
| ៥៤-អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ | | សមាជិក |
| ៥៥-អភិបាល នៃគណៈអភិបាលខេត្តសៀមរាប | | សមាជិក |
| ៥៦-អភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ | | សមាជិក |
| ៥៧-អភិបាល នៃគណៈអភិបាលខេត្តស្ទឹងត្រែង | | សមាជិក |
| ៥៨-អភិបាល នៃគណៈអភិបាលខេត្តរតនគិរី | | សមាជិក |
| ៥៩-អភិបាល នៃគណៈអភិបាលខេត្តមណ្ឌលគិរី | | សមាជិក |
| ៦០-អភិបាល នៃគណៈអភិបាលខេត្តក្រចេះ | | សមាជិក |
| ៦១-អភិបាល នៃគណៈអភិបាលខេត្តត្បូងឃ្មុំ | | សមាជិក |
| ៦២-ឯកឧត្តម **តែ ណាវុធ** | អគ្គលេខាធិការគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | សមាជិក |
| ៦៣-ឯកឧត្តម **ទិន ពន្លក** | អគ្គលេខាធិការ គ.ជ.អ.ប. | សមាជិកអចិន្ត្រៃយ៍។ |

**ប្រការ ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៥ សសរ.

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពគណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៤១៣ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សម្រេច**

**ប្រការ ១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព(**គ.ជ.អ.ច.**) ដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **សាយ សំអាល់** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ប្រធាន |
| ២-ឯកឧត្តម **ម៉ម អំណាត់** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធានទី១ |
| ៣-ឯកឧត្តម **ខៀវ មុត** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | អនុប្រធានទី២ |
| ៤-ឯកឧត្តម **ឌិត ទីណា** | រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៥-ឯកឧត្តម **គន់ វ៉ាន់ថារ៉ា** | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៦-ឯកឧត្តម **សក់ សេដ្ឋា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៧-ឯកឧត្តម **អ៊ុច បូរិទ្ធ** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៨-ឯកឧត្តម **ទី តាយី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩-ឯកឧត្តម **សាត សាមី** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១០-ឯកឧត្តម **ម៉ែន សុផល** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១១-ឯកឧត្តម **តូច ចាន់កុសល** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១២-ឯកឧត្តម **ទិន ពន្លក** | អគ្គលេខាធិការ គ.ជ.អ.ច. | សមាជិកអចិន្ត្រៃយ៍។ |

**ប្រការ ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- -ដូចប្រការ២
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :..០..៤...សរណន**

## សារាចរណែនាំ
## ស្តីពី
## ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧

### ១. សេចក្តីផ្តើម

១- មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានចែងអំពីប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំជា ៣ ដំណាក់កាល រួមមាន **ដំណាក់កាលទី១** គឺការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចាប់ពីខែមីនា ដល់ ខែឧសភា, **ដំណាក់កាលទី២** គឺការរៀបចំកញ្ចប់ថវិកា ចាប់ពីខែមិថុនា ដល់ខែកញ្ញា និង**ដំណាក់កាលទី៣** គឺការអនុម័តថវិកា ចាប់ពីខែតុលា ដល់ខែធ្នូ។ សម្រាប់ដំណាក់កាលទី១ រាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញរួចហើយនូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។ ផ្អែកលើក្របខ័ណ្ឌគោលនយោបាយនេះ រាជរដ្ឋាភិបាល ក៏បានដាក់ចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៧ ដើម្បីឱ្យគ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមឱវាទក្រសួង ស្ថាប័ននីមួយៗ ធ្វើការពន្យល់និងផ្តល់អំណះអំណាងអំពីលទ្ធភាព និងកិច្ចខិតខំក្នុងការប្រមូលចំណូលនិងបង្ហាញអំពីតម្រូវការចំណាយរយៈពេល ៣ ឆ្នាំ (២០១៧-២០១៩) សម្រាប់អនុវត្តគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ននីមួយៗ ដែលជាការរួមចំណែកអនុវត្ត **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣"** និង **"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨"** ។ នៅដំណាក់កាលទី២ នេះ រាជរដ្ឋាភិបាល ត្រូវចេញសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ដើម្បីផ្តល់គោលការណ៍ណែនាំថ្មីៗសម្រាប់ជាមូលដ្ឋាន និងជាក្របខ័ណ្ឌនៃ ការរៀបចំ កញ្ចប់ថវិកាឆ្នាំ២០១៧ របស់គ្រប់ក្រសួង ស្ថាប័ន ដោយគ្របដណ្តប់ទាំងថវិកាមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលជារដ្ឋបាលថ្នាក់ជាតិ។ ដូច្នេះ សារាចរនេះបានដាក់ចេញនូវក្របខ័ណ្ឌ និងវិធានការប្រមូលចំណូល, ការកំណត់អាទិភាពចំណាយតាមវិស័យ និងគោលការណ៍សំខាន់ៗសម្រាប់បង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា ដោយផ្អែកលើលទ្ធភាពជាក់ស្តែងនៃថវិកាជាតិអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងប្រសិទ្ធភាពនៃការអនុវត្តថវិការបស់ក្រសួង ស្ថាប័ន នាឆ្នាំកន្លងមក។ ដោយឡែកចំពោះការរៀបចំកញ្ចប់ថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានសារាចរណែនាំមួយផ្សេងទៀត ដែលត្រូវ

ដាក់ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១, ដោយឈរលើមូលដ្ឋាន និងគោលការណ៍ដែលមានចែងនៅក្នុងសារាចរណែនាំនេះ ជាពិសេសគោលការណ៍នៃការកំណត់កញ្ចប់ និងគោលការណ៍នៃការវិភាជថវិកា ដើម្បីចូលរួមបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការប្រមូលចំណូល, ប្រសិទ្ធភាពនៃការវិភាជថវិកា និងស័ក្តិសិទ្ធភាពនៃការអនុវត្តចំណាយទាំងកម្រិតបច្ចេកទេស និងប្រតិបត្តិការ ក្នុងគោលដៅរួមចំណែកកាត់បន្ថយឱនភាពថវិកា និងរក្សាអតិរេកសាច់ប្រាក់។

២- ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ស្ថិតក្នុងបរិការណ៍ដែលព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងក្រេបជញ្ជក់នូវផ្លែផ្កានៃសុខសន្តិភាព ឯកភាពជាតិ និងស្ថិរភាពនយោបាយ, ប្រកាន់ខ្ជាប់នូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស, ព្រមទាំងសម្រេចបាននូវការអភិវឌ្ឍនិងរីកចម្រើនលើគ្រប់ផ្នែក និងគ្រប់វិស័យ ជាពិសេសការសម្រេចបាននូវបង្គោលចរមួយដ៏សំខាន់ក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន គឺបានក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតទាប។ សមិទ្ធផលដ៏ធំធេងនេះ បានបង្កើតនូវមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចកម្ពុជាកាន់តែរឹងមាំ និងបង្កលក្ខខ័ណ្ឌកាន់តែអំណោយផល និងស្ថានភាពអនុគ្រោះសម្រាប់ការកសាងអនាគតកម្ពុជាមួយដ៏រុងរឿង និងត្រចះត្រចង់។ ប្រការនេះ បានផ្តល់នូវឱកាស និងភាពងាយស្រួលដល់រាជរដ្ឋាភិបាលក្នុងការបន្តអនុវត្តការកែទម្រង់ឱ្យកាន់តែស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ ដើម្បីឆ្លើយតបទៅតាមឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាជនកម្ពុជាផង និងដើម្បីឆ្លើយតបទៅនឹងដំណើរការនៃការផ្លាស់ប្តូររចនាសម្ព័ន្ធរបស់សង្គម-សេដ្ឋកិច្ចកម្ពុជាផង ព្រមទាំងការប្រែប្រួលនិមាបនកម្មសេដ្ឋកិច្ច និងភូមិសាស្ត្រនយោបាយ ទាំងក្នុងកម្រិតតំបន់ និងពិភពលោក។

៣- ការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចពិភពលោកក្នុងពេលថ្មីៗនេះ បានបង្ហាញពីសញ្ញាមួយចំនួនដែលអាចដែលធ្វើឱ្យសេដ្ឋកិច្ចពិភពលោកធ្លាក់ចូលទៅក្នុងវិបត្តិជាថ្មីម្តងទៀត ប្រសិនជាមិនមានការប្រុងប្រយ័ត្នខ្ពស់។បើទោះជាសេដ្ឋកិច្ចអាមេរិកបន្តមានកំណើនល្អ,ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោកគឺបណ្តាលមកពីការបន្តថមថយនូវកំណើនសេដ្ឋកិច្ចរបស់ប្រទេសចិន, អស្ថិរភាពក្នុងទីផ្សារហិរញ្ញវត្ថុពិភពលោក, បំណុលសាធារណៈនៃប្រទេសមួយចំនួននៅមិនទាន់បានដោះស្រាយ, ភាពធន់នៃប្រព័ន្ធធនាគារមានកម្រិតទាបរួមជាមួយនឹងភាពមានកម្រិតនៃឧបករណ៍គោលនយោបាយរូបិយវត្ថុរបស់បណ្តាប្រទេសអភិវឌ្ឍន៍ជឿនលឿន។ លើសពីនេះទៅទៀត តម្លៃប្រេងនៅលើទីផ្សារអន្តរជាតិអាចនឹងបន្តស្ថិតនៅក្នុងកម្រិតទាប, ថ្លៃកសិផលបន្តធ្លាក់ចុះ ហើយថ្លៃប្រាក់ដុល្លារអាមេរិកត្រូវបានរំពឹងថានឹងនៅបន្តកើនឡើងក្នុងឆ្នាំ២០១៦។ ដោយឡែកក្នុងឆ្នាំ២០១៧ តម្លៃប្រេង និងថ្លៃទំនិញជាអន្តរជាតិត្រូវបានរំពឹងថានឹងងើបឡើងបន្តិច ស្របពេលដែលថ្លៃប្រាក់ដុល្លារអាចនឹងធ្លាក់ចុះមកវិញ។ ទោះបីក្នុងបរិបទនេះក៏ដោយ កម្ពុជា អាចនឹងរក្សាបាននូវចលនការកំណើនសេដ្ឋកិច្ចខ្ពស់ ដោយសារការរក្សាបាននូវជីវភាពកំណើននៅក្នុងវិស័យឧស្សាហកម្ម និង សេវាកម្ម ព្រមទាំងទទួលបាននូវផលប្រយោជន៍ពីការធ្លាក់ចុះថ្លៃប្រេង ប៉ុន្តែត្រូវទទួលរងនូវហានិភ័យនៃការបន្តធ្លាក់ចុះថ្លៃកសិផល ដូចជា ស្រូវ-អង្ករ, កៅស៊ូ និងដំឡូងមី, ការកើនឡើងតម្លៃប្រាក់ដុល្លារដែលប៉ះពាល់ដល់

ភាពប្រកួតប្រជែងនៃការនាំចេញ ក៏ដូចជាការទាក់ទាញទេសចរ និងហានិភ័យនៃកំណើនឥណទានក្នុងវិស័យហិរញ្ញវត្ថុ។

៤- ជារួម ទោះបីកម្ពុជាត្រូវជួបប្រទះនូវបញ្ហាប្រឈមគ្រប់បែបយ៉ាងទាំងក្នុង និងក្រៅប្រទេសក៏ដោយ ក៏រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា, ចាប់តាំងតែពីដើមនីតិកាលរហូតមក, នៅតែអាចតស៊ូពុះពារ និងជំនះបាននូវរាល់ឧបសគ្គ និង ការលំបាកផងទាំងពួង ហើយធានាបាននូវប្រក្រតីភាពនៃដំណើរការសង្គម-សេដ្ឋកិច្ចកម្ពុជា។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាធានាបានល្អប្រសើរនូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, គ្រប់គ្រងអតិផរណាឱ្យស្ថិតក្នុងកម្រិតទាបសមរម្យ, ធានាស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងពង្រឹងឡើងថែមទៀតនូវសមត្ថភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ តាមរយៈការជំរុញការអនុវត្តវិធានការនានា សំដៅពន្លឿនពិពិធកម្មសេដ្ឋកិច្ច រួមមានជាអាទិ៍ ការបង្កើនផលិតភាពនៃវិស័យ កសិកម្ម, ការកសាងមូលដ្ឋានសេដ្ឋកិច្ចជនបទ និងការធ្វើឱ្យកាន់តែល្អប្រសើរនូវបរិយាកាសអំណោយផលសម្រាប់ទាក់ទាញការវិនិយោគឯកជន ដែលប្រការទាំងអស់នេះបានបង្កើតការងារជូនប្រជាជនកម្ពុជា, ពិសេសយុវជន ជាច្រើនសែននាក់ក្នុងមួយឆ្នាំៗ។ ជាក់ស្តែង នៅក្នុងរបាយការណ៍របស់ធនាគារពិភពលោកឆ្នាំ២០១៤ ប្រទេសកម្ពុជាត្រូវបានចាត់បញ្ចូលក្នុងក្រុមប្រទេសឯកទត្តករកំណើនទាំងប្រាំបី នៅក្នុងពិភពលោក (Olympians of Growth) ដែលមានកំណើនសេដ្ឋកិច្ចខ្ពស់និងរឹងមាំ ហើយជាងនេះទៅទៀត កាលពីពេលថ្មីៗនេះ ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)បានចាត់ទុកកម្ពុជាជាសេដ្ឋកិច្ចកូនខ្លាថ្មីមួយនៅអាស៊ី។

ដោយផ្អែកលើចំណុចខ្លាំង, កត្តាអំណោយផល, បញ្ហាប្រឈម និងហានិភ័យដូចបានគិតគូរខាងលើ ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ត្រូវបានកំណត់ឈរលើមូលដ្ឋានសុទិដ្ឋិនិយម ជាមួយនឹងការប្រុងប្រយ័ត្នខ្ពស់ ដែលរួមមានខ្លឹមសារសំខាន់ៗ ដូចខាងក្រោម៖

## ២. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧

### ២.១- ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៧

៥- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា នៅបន្តរក្សាភាពរឹងមាំនៅក្នុងឆ្នាំ២០១៥ កន្លងមក ក្នុងអត្រា ៧,០% លើសពីការប៉ាន់ស្មានកាលពីដើមឆ្នាំជាមួយនឹងអតិផរណាមធ្យមប្រចាំឆ្នាំក្នុងអត្រា១,២% និង អត្រាប្តូរប្រាក់មធ្យមប្រមាណ ៤ ០៦២ រៀល ក្នុងមួយដុល្លារសហរដ្ឋអាមេរិក។ ការបន្តមានកំណើនខ្ពស់បែបនេះបានធ្វើឱ្យចំណូលជាតិសរុបសម្រាប់ប្រជាជនម្នាក់ៗកើនឡើងដល់ ១ ២១៥ ដុល្លារអាមេរិក ជាកម្រិតចំណូលដែលកម្ពុជាត្រូវបានចាត់ទុកថាសម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប។

៦- នៅក្នុងឆ្នាំ២០១៦ និង ឆ្នាំ២០១៧ តាមការព្យាករ កម្ពុជានឹងសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧,១%, ហើយផ.ស.ស តាមថ្លៃចរន្តឆ្នាំ២០១៦ ត្រូវបានប៉ាន់ស្មានស្មើនឹងចំនួន ៨០ ៤១៣ ០២០ លានរៀល និង ផ.ស.ស តាមថ្លៃចរន្តឆ្នាំ២០១៧ ត្រូវបានគ្រោងចំនួន ៨៨ ១៩១ ៣០០ លានរៀល។ កំណើននេះបានមកពី៖

- វិស័យកសិកម្ម អាចនឹងសម្រេចបានកំណើនតែប្រមាណ ០,១១% នៅឆ្នាំ២០១៦ ដោយសារការបន្តធ្លាក់ចុះនៃផលនេសាទ និងទិន្នផលស្រូវដែលបណ្តាលមកពីបញ្ហាអាកាសធាតុ, ការធ្លាក់ចុះនៃកម្ពស់

ទឹកទន្លេ និងការបន្តធ្លាក់ចុះនៃតម្លៃកសិផលនៅលើទីផ្សារអន្តរជាតិ និងអាចបន្តសម្រេចបានកំណើនទាបដដែលក្នុងអត្រា ០,១៤% នៅឆ្នាំ២០១៧ ដោយសារការថមថយនៃកំណើនផលិតភាពនៃដំណាំស្រូវដែលបណ្តាលមកពីកង្វះការវិនិយោគលើប្រព័ន្ធធារាសាស្ត្រខ្នាតតូច, កង្វះការផ្គត់ផ្គង់ពូជសុទ្ធដែលមានគុណភាព និងការផ្តល់សេវាបច្ចេកទេស និងកំណើនតិចតួចនៅក្នុងការចិញ្ចឹមសត្វ។ ដូច្នេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហាផលិតភាពទាបនេះ តាមរយៈការបន្តវិនិយោគបន្ថែមលើការកសាងប្រព័ន្ធធារាសាស្ត្រខ្នាតតូច, ការបង្កើនការផលិតពូជសុទ្ធដែលមានគុណភាព, ការផ្សព្វផ្សាយកសិកម្ម និងការសិក្សាស្រាវជ្រាវ, ព្រមទាំងជំរុញការផ្តល់ហិរញ្ញប្បទាន។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ផងដែរលើការជំរុញមច្ឆវប្បកម្ម និងការចិញ្ចឹមសត្វបន្ថែម ដោយផ្សារភ្ជាប់ជាមួយនឹងការគិតគូរទៅដល់តុល្យភាពបរិស្ថាន។

- វិស័យឧស្សាហកម្ម អាចនឹងសម្រេចបានកំណើនខ្ពស់ក្នុងអត្រា ១១,៨% នៅឆ្នាំ២០១៦ និងក្នុងអត្រា ១០,៩% នៅឆ្នាំ២០១៧ ដោយសារការបន្តកើនឡើងនៃវិស័យកាត់ដេរ និងផលិតកម្មក្នុងស្រុកផ្សេងទៀត។ វិស័យកាត់ដេរ ត្រូវបានរំពឹងថានឹងបន្តរក្សាកំណើនខ្ពស់ក្នុងអត្រា ១០,៦% នៅឆ្នាំ២០១៦ និង ៩,៨% នៅឆ្នាំ២០១៧ ដោយសារតែការបន្តកើនឡើងនៃតម្រូវការផលិតផលកាត់ដេរនៅលើទីផ្សារពិភពលោក ជាពិសេសពីប្រទេសដៃគូនាំចេញសំខាន់ៗរបស់កម្ពុជា រួមមាន សហគមន៍អឺរ៉ុប, សហរដ្ឋអាមេរិក និងជប៉ុន, គួបផ្សំនឹងស្ថានភាពកាន់តែល្អប្រសើរឡើងនៃទំនាក់ទំនងវិជ្ជាជីវៈក្នុងប្រទេសកម្ពុជា។ ទោះយ៉ាងនេះក្តី វិស័យនេះក៏កំពុងជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចជា បញ្ហាផលិតភាពទាប, ការកើនឡើងនៃការប្រកួតប្រជែងក្នុងតំបន់, កំណើនប្រាក់ឈ្នួលអប្បបរមា និងការកើនឡើងនៃតម្លៃប្រាក់ដុល្លារដែលធ្វើឱ្យភាពប្រកួតប្រជែងធ្លាក់ចុះ។ ក្នុងន័យនេះ កម្ពុជាត្រូវផ្តោតសំខាន់លើការពង្រឹងភាពប្រកួតប្រជែងរបស់ខ្លួន ដើម្បីរក្សានិរន្តរភាពកំណើននៃវិស័យកាត់ដេរ ក៏ដូចជាការត្រៀមខ្លួនជាស្រេច ដើម្បីចាប់យកឱកាសនៃបម្លាស់ទីរោងចក្រចេញពីប្រទេសចិន ខណៈដែលល្បឿនពិពិធកម្មផលិតផលនាំចេញរបស់កម្ពុជានៅមានកម្រិត។

- វិស័យសំណង់ នឹងមានកំណើនថមថយបន្តិចក្នុងអត្រា ១៥,០% នៅឆ្នាំ២០១៦ និងក្នុងអត្រា ១២,៤% នៅឆ្នាំ២០១៧ ដោយសារការកើនឡើងដ៏លើសលប់នៃការផ្គត់ផ្គង់នៅក្នុងឆ្នាំកន្លងទៅ ព្រមទាំងការបន្តរឹតបន្តឹងការផ្តល់ឥណទានដល់វិស័យនេះ។ ការធ្លាក់ចុះបន្តិចនៃកំណើនរបស់វិស័យសំណង់ និងអចលនទ្រព្យអាចជាសញ្ញាល្អមួយ ព្រោះថាវិស័យនេះកំពុងឈានចូលដំណាក់កាល ដែលអាចបង្កហានិភ័យនៅក្នុងវិស័យហិរញ្ញវត្ថុ និងទាមទារឱ្យមានការត្រួតពិនិត្យឱ្យបានតឹងរ៉ឹង និងជាប្រចាំ។

- ជាមួយគ្នានេះ គ្រឿងបង្គុំអេឡិចត្រូនិក និងវិស័យម្ហូបអាហារ, ភេសជ្ជៈ និងថ្នាំជក់ បានក្លាយជាវិស័យដែលមានសន្ទុះកំណើនលឿនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ប្រការនេះបានឆ្លុះបញ្ចាំងពីការកើនឡើងនៃពិពិធកម្មផលិតផលនាំចេញ និងការកើនឡើងនៃតម្រូវការប្រើប្រាស់របស់ប្រជាជនក្នុងស្រុក ដែលជាសញ្ញាមួយល្អសម្រាប់កម្ពុជា ក៏ដូចជាការឆ្លុះបញ្ចាំងពីគោលនយោបាយដ៏ត្រឹមត្រូវ ដែលរាជរដ្ឋាភិបាលបានដាក់ចេញកន្លងមកផងដែរ។ វិស័យនេះ កំពុងដើរតួយ៉ាងសំខាន់ក្នុងការបំពេញចំណែកថមថយនៃកំណើន របស់វិស័យសំណង់។ វិស័យម្ហូបអាហារ, ភេសជ្ជៈ និងថ្នាំជក់ ត្រូវបានព្យាករថានឹងមានអត្រាកំណើន ៧,៤% នៅឆ្នាំ២០១៦ និង ៧,៨% នៅឆ្នាំ២០១៧ ដែលគាំទ្រដោយកំណើនកាន់តែខ្លាំងនៃការប្រើប្រាស់ និងជាពិសេសគម្រោងវិនិយោគបន្ថែមរបស់ក្រុមហ៊ុនវិនិយោគធំៗ។

- វិស័យសេវាកម្ម ត្រូវបានរំពឹងថានឹងបន្តសម្រេចបានកំណើនខ្ពស់ក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ ពោលគឺ ៧,១% សម្រាប់ឆ្នាំ២០១៦ និង ៦,៨% នៅឆ្នាំ២០១៧ ទោះបីវិស័យទេសចរណ៍បន្តមានកំណើនទាបក្នុងអត្រា ២,២% និង ២,១% រៀងគ្នា នៅឆ្នាំ២០១៦ និង ២០១៧។ ការថមថយកំណើននៃវិស័យទេសចរណ៍ បណ្តាលមកពីការធ្លាក់ចុះចំណាយរបស់ភ្ញៀវទេសចរ, ការកើនឡើងតម្លៃនៃប្រាក់ដុល្លារ, ការបន្តធ្លាក់ចុះនៃចំនួនភ្ញៀវទេសចរមកពីបណ្តាប្រទេសសំខាន់ៗ ដូចជាជប៉ុន, កូរ៉េ, រុស្ស៊ី និងចិន, និងកង្វះពិពិធកម្មផលិតផលនិងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍។ ទោះជាយ៉ាងនេះក្តី ជារួម ការថមថយកំណើននៃវិស័យទេសចរណ៍ អាចត្រូវបានបំពេញវិញដោយការកើនឡើងនៃវិស័យលក់ដុំ-លក់រាយ និងវិស័យដឹកជញ្ជូននិងទូរគមនាគមន៍ ដែលឆ្លុះបញ្ចាំងពីកំណើនតម្រូវការក្នុងស្រុក។ ស្របគ្នានឹងភាពមិនសូវអំណោយផលនៃកត្តាខាងក្រៅ ចាំបាច់ត្រូវបន្តធ្វើពិពិធកម្មទាំងគោលដៅ និងផលិតផលទេសចរណ៍ឱ្យអស់សក្តានុពល ដើម្បីបង្កើនតម្លៃបន្ថែមនៃវិស័យនេះក្នុងសេដ្ឋកិច្ចជាតិ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងបន្តយកចិត្តទុកដាក់ផងដែរលើហានិភ័យដែលអាចកើតឡើងពីវិស័យអចលនទ្រព្យ និងវិស័យមីក្រូហិរញ្ញវត្ថុ ព្រមទាំងជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឱ្យកាន់តែខ្លាំងក្លា។

- អតិផរណាស្ថិតនៅក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន ទោះបីមានការកើនឡើងនៃថ្លៃសម្ភារៈប្រើប្រាស់ និងម្ហូបអាហារមួយចំនួនក៏ដោយ។ អត្រាអតិផរណាជាមធ្យមនៅឆ្នាំ២០១៦ និងឆ្នាំ២០១៧ ត្រូវបានរំពឹងថានឹងកើនឡើងដល់១,៩% និង ៣,៣% រៀងគ្នា បន្ទាប់ពីធ្លាក់ចុះដល់ ១,២% ក្នុងឆ្នាំ២០១៥។ អត្រាប្តូរប្រាក់ត្រូវបានរំពឹងថានឹងមានស្ថិរភាព ដែលមានតម្លៃជាមធ្យម ៤០៥០ រៀលក្នុងមួយដុល្លារអាមេរិកនៅឆ្នាំ២០១៦ និង២០១៧ ដោយសារកំណើនសេដ្ឋកិច្ចខ្ពស់ និងការជឿទុកចិត្តពីសាធារណជន ពិសេស ការបន្តអនុវត្តគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈបានល្អ និងគោលនយោបាយរូបិយវត្ថុសមស្រប។

- នៅឆ្នាំ២០១៥ ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ) បានថយចុះមកត្រឹម៩,៣% នៃ ផ.ស.ស ដោយសារការកើនឡើងនៃការនាំចេញ បន្ទាប់ពីមានកម្រិត ៩,៨% នៃផ.ស.ស ក្នុងឆ្នាំ២០១៤។ តាមការព្យាករ ឱនភាពគណនីចរន្តអាចបន្តធ្លាក់ចុះដល់ ៩,១% នៃផ.ស.ស នៅឆ្នាំ២០១៦ និង ៨,៥% នៃ ផ.ស.ស នៅឆ្នាំ២០១៧។ និន្នាការនៃការធ្លាក់ចុះនេះ គឺដោយសារសមត្ថភាពនៃការនាំចេញរបស់កម្ពុជាមានការកើនឡើងជាលំដាប់ ទន្ទឹមនឹងផលិតផល និងវត្ថុធាតុដើមមួយចំនួនចាប់ផ្តើមមានមូលដ្ឋានផលិតនៅក្នុងស្រុកជំនួសឱ្យការនាំចូលជាបណ្តើរៗ។ នៅឆ្នាំ២០១៦ ទុនបម្រុងនឹងមានទំហំ ៥ ៤៥៩ លានដុល្លារអាមេរិក និងអាចកើនឡើងដល់ ៥ ៩០៥ លានដុល្លារអាមេរិក នៅឆ្នាំ២០១៧ ដែលធានាបានប្រមាណជាង ៤,៥ ខែ នៃការនាំចូលទំនិញ និងសេវាប្រើប្រាស់ក្នុងស្រុក។

- ជារួម ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះត្រូវបានរៀបចំឡើង ដើម្បីរក្សាឱ្យបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចតាមរយៈការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព, ស្ថិរភាពតម្លៃ, ការបង្កើតការងារ និងចីរភាពបំណុល។ ដើម្បីសម្រេចគោលបំណងខាងលើ រាជរដ្ឋាភិបាលកំណត់គោលដៅកំណើន ផ.ស.ស ឱ្យសម្រេចបាន ៧,១% និង ៦,៩% រៀងគ្នា សម្រាប់ឆ្នាំ២០១៦ និងឆ្នាំ២០១៧។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលនឹងខិតខំគ្រប់គ្រងអតិផរណាជាមធ្យមប្រចាំឆ្នាំឱ្យស្ថិតក្នុងរង្វង់ ៣,៥% ក្នុងមួយឆ្នាំពោលគឺនៅក្នុងរង្វង់ ១,៩% នៅឆ្នាំ២០១៦ និង ៣,៣% នៅឆ្នាំ២០១៧។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងធានាឱ្យបានស្ថិរភាពអត្រាប្តូរប្រាក់

រៀលឱ្យស្ថិតនៅក្នុងរង្វង់ ៤ ០៥០ រៀលក្នុងមួយដុល្លារអាមេរិក ដោយខិតខំជំរុញបដិដុល្លារូបិយកម្មសេដ្ឋកិច្ច នៅចំពោះមុខ និងរយៈពេលវែង។ (សូចនាករម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៥-២០១៩ មាននៅក្នុងឧបសម្ព័ន្ធ១ ភ្ជាប់ជាមួយ)។

**២.២- ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ២០១៧**

៨- ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ថវិកាឆ្នាំ២០១៧ ត្រូវបានរៀបចំដោយឈរលើមូលដ្ឋាននៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៧ និង "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣**" និង "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**" ដោយមានគោលបំណងសំខាន់ៗ ដូចតទៅ៖

- បន្តធានាអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដើម្បីបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កានៃកំណើន ប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន,
- បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ និងធានាការពារអធិបតេយ្យ និងបូរណភាពទឹកដី,
- បន្តធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ព្រមទាំងធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព,
- បន្តផ្តល់អាទិភាពដល់ការតម្លើងប្រាក់បៀវត្សរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ឆ្ពោះទៅសម្រេចគោលដៅឱ្យបានជាង ១ លានរៀល នៅឆ្នាំ២០១៨ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងបង្កើនកម្រិតជីវភាពរបស់មន្ត្រីរាជការឱ្យកាន់តែល្អប្រសើរ, ដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ (២០១៥-២០១៨), ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ,
- បន្តកិច្ចខិតខំប្រឹងប្រែងខ្លាំងក្លាជាងមុនក្នុងការប្រមូលចំណូល ដើម្បីបន្តសម្រេចបានតាមទិសដៅដាក់ចេញក្នុង**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម (២០១៤-២០១៨)** ជាពិសេស គឺរក្សាបានចីរភាពចំណូលជាមួយនឹងកំណើនខ្ពស់ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក,
- ពង្រឹង និងពង្រីកលំហថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិ ដើម្បីទប់ទល់វិបត្តិកលិយុគ និងហានិភ័យ ផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ, និងបង្កើនចំណាយវិនិយោគផ្ទាល់ដោយថវិកាជាតិ ដើម្បីបង្កើនឯករាជ្យភាពនៃថវិកា និងកាត់បន្ថយជាបណ្តើរៗនូវការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស,
- បន្តពង្រឹងការអនុវត្តគោលនយោបាយគ្រប់គ្រងបំណុលសាធារណៈ ឱ្យស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន និងប្រកបដោយចីរភាព,
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ការលើកកម្ពស់សេវាសុខាភិបាល អាហារូបត្ថម្ភ និងសេវាសន្តិសុខសង្គម,

- បន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ទាំងផ្នែករឹង និងផ្នែកទន់សម្រាប់គាំទ្រកំណើន និងការអភិវឌ្ឍ ជាពិសេស ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធធារាសាស្ត្រស្រោចស្រព អគ្គិសនី ទឹកស្អាត សាលារៀន និង មន្ទីរពេទ្យ ។ល។ *ព្រមជាមួយនឹងការផ្តល់អាទិភាពលើហេដ្ឋារចនាសម្ព័ន្ធថ្មីៗ និងសកម្មភាពអភិវឌ្ឍន៍វិស័យកសិកម្ម ដែលមានភាពធន់ទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងការផ្ទុះជំងឺ ដើម្បីបញ្ចៀសការខូចខាតពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយទៅលើការអភិវឌ្ឍសេដ្ឋកិច្ច,*
- បន្តផ្តល់អាទិភាពដល់សកម្មភាពថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបានកសាងរួច ជាពិសេស ផ្លូវថ្នល់ និង ប្រព័ន្ធធារាសាស្ត្រស្រោចស្រព,
- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្មនិងវិស័យគាំទ្រ ដើម្បីជំរុញផលិតភាព តម្លៃបន្ថែម និង ជំរុញការកែច្នៃ និងនាំចេញផលិតផលកសិ-ឧស្សាហកម្ម និងកសិផល ការចិញ្ចឹមសត្វ និងវារីវប្បកម្ម, រួមទាំងបន្តការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ,
- ជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា២០១៥-២០២៥,
- បន្តអនុវត្តកំណែទម្រង់សំខាន់ៗ រួមទាំង ការពង្រឹងស្ថាប័នសាធារណៈ និងប្រព័ន្ធអភិបាលកិច្ច,
- លើកកម្ពស់គុណភាព និងពង្រីកការទទួលបានភាពពេញចិត្ត និងប្រសិទ្ធភាពនៃសេវាសាធារណៈ
- ធានាជោគជ័យនៃការបោះឆ្នោតឃុំ-សង្កាត់ ឆ្នាំ២០១៧។

៩- ក្នុងបរិបទ និងទស្សនៈវិស័យម៉ាក្រូសេដ្ឋកិច្ច និងក្នុងទិសដៅសម្រេចឱ្យបាននូវគោលបំណងខាងលើ រាជរដ្ឋាភិបាលបានកំណត់ក្របខ័ណ្ឌថវិកាឆ្នាំ២០១៧ រួមជាមួយនឹងវិធានការគោលនយោបាយជាក់លាក់ទាំងផ្នែកចំណូល និងផ្នែកចំណាយសម្រាប់ឆ្នាំ២០១៧ ដូចខាងក្រោម៖

### ២.២.១- ក្របខ័ណ្ឌចំណូលថវិកាឆ្នាំ២០១៧

១០- គម្រោងចំណូលថវិកាឆ្នាំ២០១៧ ត្រូវបានកំណត់ដូចខាងក្រោម៖

- ចំណូលសរុបក្នុងប្រទេសថវិកាជាតិសម្រាប់ឆ្នាំ២០១៧ គ្រោងសម្រេចឱ្យបាន ១៨,៤១% នៃផ.ស.ស. គឺមានកំណើន ០,៥៥ ពិន្ទុភាគរយនៃផ.ស.ស. ឬ កើនឡើង ១៣,០% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ (ហៅកាត់ថា ច្បាប់ថវិកាឆ្នាំ២០១៦) ក្នុងនោះ ៖

  - ចំណូលចរន្តថវិកាជាតិត្រូវសម្រេចឱ្យបានប្រមាណ ១៨,២៤% នៃផ.ស.ស. គឺមានកំណើន ០,៥៥ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៣,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៦។ **ចំណូលពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា** ត្រូវគ្រោងសម្រេចឱ្យបាន ៨,២៩% នៃផ.ស.ស. គឺមានកំណើន ០,០២ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ៩,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៦, **ចំណូលពីអគ្គនាយកដ្ឋានពន្ធដារ**ត្រូវគ្រោងសម្រេចឱ្យបាន ៦,៦៩% នៃផ.ស.ស. គឺមានកំណើន ០,៥៩ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ២០,៣% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៦, និង**ចំណូលមិនមែនសារពើពន្ធ** ត្រូវគ្រោងសម្រេចឱ្យបាន ២,២១% នៃផ.ស.ស. គឺថយចុះ ០,១៥ ពិន្ទុភាគរយនៃផ.ស.ស. ប៉ុន្តែមានកំណើន ២,៧% ធៀបនឹង ច្បាប់ថវិកាឆ្នាំ២០១៦។

- **ចំណូលមូលធន**ក្នុងប្រទេស ត្រូវសម្រេចឱ្យបាន០,១៧% នៃផ.ស.ស. គឺមានកំណើន ០,០១ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៣,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៦។
- ចំណែកឯ **ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈ** គ្រោងសម្រេចឱ្យបាន ៤,៨៦%នៃផ.ស.ស. គឺមានកំណើន ០,០៥ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១០,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៦ ហើយ**មូលនិធិទ្រទ្រង់ថវិកា** គ្រោងសម្រេចឱ្យបាន ០,១៨%នៃផ.ស.ស.។

១១- ដើម្បីសម្រេចគោលដៅចំណូលសរុបខាងលើនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើការជំរុញ និងពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយសម្រាប់រយៈពេលខ្លី និងមធ្យម ស្របតាម **យុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨** ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ក្នុងផ្នែកគយនិងរដ្ឋាករ ផ្នែកពន្ធដារ និងផ្នែកមិនមែនសារពើពន្ធ។ ជាពិសេស រាជរដ្ឋាភិបាលនឹងបន្តប្រឹងប្រែងខ្លាំងក្លាជាងមុន ក្នុងការលើកកម្ពស់វប្បធម៌បង់ពន្ធ តាមរយៈការកែសម្រួលនិងការធ្វើសាមញ្ញកម្មនៃសេវាបង់ពន្ធដល់អ្នកបង់ពន្ធដើម្បីលើកកម្ពស់អនុលោមភាព, បន្តពង្រឹងការបង្ក្រាបអំពើរត់ពន្ធ និងការគេចវេះពន្ធគ្រប់រូបភាពឱ្យដល់ឫសគល់ និងការពង្រឹងការគៀរគរបន្ថែមនូវចំណូលមិនមែនសារពើពន្ធតាមបណ្តាក្រសួង ស្ថាប័ននានា។

**ក.១- ផ្នែកចំណូលពន្ធដារ**

១២- វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ២០១៧ រួមមាន៖

- កំណត់គោលដៅប្រមូលបំណុលពន្ធនៅតាមនាយកដ្ឋាននិងសាខាពន្ធដារខេត្ត-ខណ្ឌ និងអនុវត្តយ៉ាងម៉ឺងម៉ាត់ នូវវិធានការតឹងទារ (ចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ) ចំពោះអ្នកជំពាក់បំណុលពន្ធធំៗ ដែលមិនតវ៉ា និង មានបំណុលពន្ធថ្មីៗ,
- បន្តពង្រឹងប្រតិបត្តិការចុះបញ្ជីពន្ធដារតាមប្រព័ន្ធថ្មី និងបន្តធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសទាំងអស់ដែលបានចុះបញ្ជីពន្ធដារក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងប្រមូលចំណូល,
- បន្តតាមដាន និងជំរុញការអនុវត្តនូវយុទ្ធសាស្ត្រពង្រឹងសេវាអ្នកជាប់ពន្ធ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ក្នុងនោះរួមមាន យន្តការសម្របសម្រួលរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋាន, កម្មវិធីផ្តល់សេវាអ្នកជាប់ពន្ធ, ការបណ្តុះបណ្តាលក្រុមមន្ត្រីបង្គោល ដែលមានជំនាញសេវាអ្នកជាប់ពន្ធ និងការផ្សព្វផ្សាយ ។ល។,
- បន្តកែលម្អបន្ថែមលើការចាត់ចែងលិខិតប្រកាសពន្ធ ដោយផ្តោតការយកចិត្តទុកដាក់លើ៖
  *ទី១*- ការជំរុញបន្ថែមលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងការប្រកាសពន្ធ និងបង់ប្រាក់ពន្ធ,
  *ទី២*- ពង្រឹងការអនុវត្តវិធានការលុបចោលការចុះបញ្ជី ឬដកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមជាបណ្តោះអាសន្នចំពោះអ្នកជាប់ពន្ធ ដែលមិនបានដាក់លិខិតប្រកាសអាករលើតម្លៃបន្ថែមក្នុង

រយៈពេល០៣ ខែជាប់គ្នា,

*ទី៣-* បន្តអនុវត្តការកំណត់អត្រាគោលដៅនៃការដាក់លិខិតប្រកាស ឱ្យបានខ្ពស់ជាអតិបរមា បន្ទាប់ពីបានធ្វើការលុបឈ្មោះអ្នកជាប់ពន្ធចេញពីបញ្ជី ដើម្បីវាយតម្លៃហានិភ័យអ្នកជាប់ពន្ធឱ្យបានទាន់ពេលវេលា,

- ពង្រឹងបន្ថែមលើប្រសិទ្ធភាព និងគុណភាពនៃការធ្វើសវនកម្មពន្ធដារទាំងសវនកម្មមានកម្រិត និងសវនកម្មពេញលេញ ដើម្បីបង្កើនចំណូលពន្ធដារ ដោយផ្តោតសំខាន់លើ៖

*ទី១-* ជ្រើសរើសសវនករបន្ថែម ឱ្យស្របទៅនឹងកំណើនចំនួនសហគ្រាស និងប្រសិទ្ធភាពការងារ,

*ទី២-* រៀបចំសារាចរណែនាំស្តីពីការធ្វើសវនកម្មលើវិស័យសំខាន់ៗមួយចំនួន រួមមាន ធនាគារ, សំណង់, ដឹកជញ្ជូន និងទូរគមនាគមន៍ ដើម្បីឱ្យសវនករងាយស្រួលក្នុងការអនុវត្តសវនកម្ម និងបង្កើនប្រសិទ្ធភាពសវនកម្ម,

*ទី៣-* រៀបចំសារាចរណែនាំស្តីពីការផ្ទេរថ្លៃ (Transfer Pricing),

- រៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មានពន្ធដារ តាមដំណាក់កាលនៃការអនុវត្ត, តម្រូវការរបស់អ្នកប្រើប្រាស់ និងតម្រូវការធនធានសម្ភារៈបរិក្ខារ និងរៀបចំផែនការធ្វើលទ្ធកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយផ្អែកទៅតាមផែនការយុទ្ធសាស្ត្រសម្រាប់គាំទ្រដល់ការងារសេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស និងការធ្វើសវនកម្ម និងការគ្រប់គ្រងបំណុលពន្ធ,
- រៀបចំ និងដាក់ឱ្យអនុវត្តផែនការផ្តល់សេវាអ្នកជាប់ពន្ធធំបំផុតចំនួន១៥០។

**ក.២- ផ្នែកចំណូលគយ និងរដ្ឋាករ**

១៣- វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ២០១៧ រួមមាន៖

- ពង្រឹងវិធានការបង្ការ, ទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធគ្រប់រូបភាព ជាពិសេសលើមុខទំនិញដូចជា ប្រេង, គ្រឿងអេឡិចត្រូនិក, សម្ភារៈសំណង់ និងយានយន្តឱ្យកាន់តែមានប្រសិទ្ធភាព,
- បន្តពង្រឹងការត្រួតពិនិត្យ និងបញ្ចេញទំនិញ ដោយយកចិត្តទុកដាក់ទៅលើការបន្តពង្រឹងប្រសិទ្ធភាព នៃការផ្ទៀងផ្ទាត់សង្គតិភាព និងអនុលោមភាពនៃឯកសារនាំចេញនាំចូល,
- បន្តការងារចែករំលែកព័ត៌មានរវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ ដោយកំណត់ពីវិសាលភាព និងតម្រូវការ ដោយធ្វើឡើងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន,
- ពិនិត្យលទ្ធភាពក្នុងការពិចារណាបញ្ចប់ការអនុគ្រោះអាករលើតម្លៃបន្ថែម ចំពោះការនាំចូលម៉ូតូ ដោយយកតម្លៃបន្ថែមពេញវិញ ដើម្បីប៉ះប៉ូវលើការបាត់បង់ពន្ធគយជាង ៥០% ពីការនាំចូលម៉ូតូ ដោយសារមានរោងចក្រតម្លើងនៅក្នុងប្រទេស,
- ពង្រឹងកិច្ចសហការជាមួយសហគមន៍កំពង់ផែ ដោយរៀបចំប្រព័ន្ធប្រកាសគយដោយស្វ័យប្រវត្តិតាមរយៈការតភ្ជាប់ទៅវិញទៅមកជាមួយប្រព័ន្ធរបស់សហគមន៍កំពង់ផែ,
- បន្តពង្រីក និងធ្វើបច្ចុប្បន្នកម្មប្រព័ន្ធទិន្នន័យតម្លៃគិតពន្ធគយ ឱ្យស្របតាមតម្លៃទិញលក់ពិត ជាពិសេស ទំនិញដែលមានវេទយិតភាពលើចំណូល,

- ពិនិត្យលទ្ធភាព និងអនុវត្តការធ្វើវិមជ្ឈការការងារផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ចំពោះមុខទំនិញវេទយិតភាព លើចំណូលពន្ធគយមួយចំនួន និងធ្វើវិមជ្ឈការទៅការិយាល័យគយទូទាំងខេត្ត ក្រុង លើការងារផ្ទៀងផ្ទាត់ តម្លៃគិតពន្ធគយទំនិញមិនមានវេទយិត ដើម្បីជានាប្រសិទ្ធភាពក្នុងការប្រមូលចំណូលពន្ធគយ,
- ធ្វើបច្ចុប្បន្នកម្មជាប្រចាំនូវលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ហានិភ័យ និងបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ គ្រប់គ្រងហានិភ័យគយ ដោយរក្សាឱ្យបាននូវការសម្ងាត់វិជ្ជាជីវៈ,
- បន្តពង្រឹងយន្តការឆ្លងកាត់ តាមរយៈការពង្រឹងអនុលោមភាពនៃការប្រើប្រាស់ទំនិញក្រោមរបបអនុគ្រោះពន្ធគយ និងការពង្រឹងសមត្ថភាពមន្ត្រីក្នុងការរៀបចំដាក់បណ្តឹងទៅតុលាការ,
- បន្តតាមដាន និងសិក្សាលើការបាត់បង់ចំណូលពន្ធអាករគយពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងប្រទេសដៃគូផ្សេងទៀត សម្រាប់ជាមូលដ្ឋានក្នុងការកែតម្រូវវិធានការឆ្លើយតបដែលមានស្រាប់ និងបង្កើតឡើងវិធានការចាំបាច់បន្ថែម,
- ពង្រឹងយន្តការភាពជាដៃគូជាមួយវិស័យឯកជនក្នុងការដោះស្រាយបញ្ហា ឬកង្វល់នានារបស់ធុរជន,
- បន្តពង្រឹងការគោរពប្រតិបត្តិក្រមសីលធម៌របស់មន្ត្រីគយ និងពង្រឹងសមត្ថភាពមន្ត្រីគយ តាមរយៈការបណ្តុះបណ្តាលជំនាញចាំបាច់ទាំងឡាយ,
- ពង្រឹង និងធ្វើបច្ចុប្បន្នកម្មប្រព័ន្ធទិន្នន័យតម្លៃគិតពន្ធគយឱ្យស្របតាមតម្លៃទំនិញលក់ពិត,
- កំណត់ទិន្នន័យអប្បបរមា ដែលត្រូវមានលើវិក្កយបត្រពាណិជ្ជកម្មក្នុងទម្រង់ដាក់លាក់តាមបទប្បញ្ញត្តិជាធរមាន។

**ក.៣- ផ្នែកចំណូលមិនមែនសារពើពន្ធ**

១៤- វិធានការបន្តសម្រាប់អនុវត្តក្នុងឆ្នាំ២០១៧ រួមមាន៖

- រៀបចំ និងដាក់ឱ្យអនុវត្តជាជំហានៗនូវកម្រៃសេវាធ្វើដំណើរ ដោយក្នុងនោះ អាចចាប់ផ្តើមពីកម្រៃសេវាធ្វើដំណើរ តាមផ្លូវអាកាសមុន ដើម្បីប៉ះប៉ូវដល់លទ្ធភាពនៃការបាត់បង់ចំណូលពីការបន្តផ្តល់ការលើកលែងទិដ្ឋាការនាពេលខាងមុខ,
- សិក្សា និងវាយតម្លៃលើគោលនយោបាយតម្លៃសម្បទានដីសេដ្ឋកិច្ច, កម្រៃអាជ្ញាប័ណ្ណ, ការបង់កម្រៃ នៃការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុន, កម្រៃសួយសារប្រេងកាត និងរ៉ែនានា ដោយពិចារណាទៅលើភាពទាក់ទាញសម្រាប់អ្នកវិនិយោគ និងផលប្រយោជន៍សមស្របជូនរាជរដ្ឋាភិបាល,
- ជំរុញការរៀបចំ និងអនុម័តច្បាប់ស្តីពីការគ្រប់គ្រងកាស៊ីណូ និងបន្តតាមដានការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងបង្កើតលិខិតបទដ្ឋានគតិយុត្តបន្ថែម ដើម្បីធ្វើការតាមដានវឌ្ឍនភាពក្នុងក្របខ័ណ្ឌអន្តរក្រសួងនៃ **"យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ២០១៤-២០១៨"**,
- បន្តពង្រឹងប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ តាមរយៈការបន្តធ្វើសវនកម្មក្រសួង ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោម

ជាតិ និងបន្តពង្រឹង និងដាក់ឱ្យអនុវត្តធ្វើបញ្ជីសារពើភ័ណ្ឌសម្បទានដីសេដ្ឋកិច្ច, ទ្រព្យសម្បត្តិរដ្ឋ រួមបញ្ចូល ទាំងទ្រព្យដែលរឹបអូសបានពីបទល្មើសផ្សេងៗ, ការបញ្ចប់គម្រោងនានារបស់ស្ថាប័នថ្នាក់ជាតិ, ថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈ, អំណោយរបស់ដៃគូអភិវឌ្ឍ, អង្គការក្រៅរាជរដ្ឋាភិបាល និងសប្បុរសជននានា,

- បន្តពង្រឹងការប្រមូលចំណូលពីអាករស្ថានទូត តាមរយៈការបន្តជំរុញឱ្យគ្រប់ចំណុចគោលដៅដែលមានសមត្ថកិច្ចផ្តល់ទិដ្ឋាការជូនភ្ញៀវទេសចរ រួមមានច្រកអន្តរជាតិ និងស្ថានទូត, ស្ថានអគ្គកុងស៊ុល, រៀបចំរបាយការណ៍ស្តីពីចំណូលអាករស្ថានទូត, ស្ថានភាពប្រើប្រាស់សន្លឹកទិដ្ឋាការ និងស្ថានភាពប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ប្រចាំគ្រាឱ្យបានទៀងទាត់និងច្បាស់លាស់, និងឈានទៅរៀបចំសារាចរណែនាំស្តីពីការគ្រប់គ្រងចំណូលពីអាករស្ថានទូត និងគ្រប់គ្រងសន្លឹកទិដ្ឋាការ,
- បន្តពង្រឹងការគ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ តាមរយៈការរៀបចំឡើងវិញ និងអនុវត្តក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីបង្កើនតម្លាភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ប្រភពហិរញ្ញប្បទាន ក្នុងគោលដៅជំរុញការអភិវឌ្ឍស្ថាប័នគ្រឹះស្ថានសាធារណៈរដ្ឋបាល,
- រៀបចំនិងដាក់ឱ្យអនុវត្តការបង់កម្រៃនៅក្នុងការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានា និងអនុវត្តការបង់ពន្ធប្រថាប់ត្រាតាមច្បាប់ជាធរមាន,
- ពិនិត្យលទ្ធភាពដាក់អង្គភាពរដ្ឋទាំងឡាយណា ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឱ្យទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។

### ២.២.២- ក្របខ័ណ្ឌចំណាយថវិកាឆ្នាំ២០១៧

១៥- គម្រោងចំណាយថវិកាឆ្នាំ២០១៧ ត្រូវបានកំណត់ និងវិភាជ ដូចខាងក្រោម៖

- **ចំណាយសរុបថវិការដ្ឋ**សម្រាប់ឆ្នាំ២០១៧ ត្រូវបានគ្រោងស្មើនឹង ២៣,៣០% នៃផ.ស.ស. គឺមានកំណើន ០,៥៦ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១២,៤% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ (ហៅកាត់ថា ច្បាប់ថវិកាឆ្នាំ២០១៦)។ ក្នុងនោះ **ចំណាយចរន្តថវិការដ្ឋ**នឹងកម្រិតត្រឹម ១៤,៨០% នៃផ.ស.ស. គឺមានកំណើន ០,០៩ ពិន្ទុភាគរយ នៃផ.ស.ស. ឬកើនឡើង ១០,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៦ ដោយផ្តោតអាទិភាពជាពិសេសលើការបង្កើន **ចំណាយបៀវត្ស** សម្រាប់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឱ្យបាន ៥២,៧២% នៃចំណាយចរន្តសរុប ឬស្មើប្រមាណ ៧,៨០% នៃផ.ស.ស.។ **ចំណាយមូលធន** ត្រូវបានគ្រោងស្មើនឹង ៨,៥០% នៃផ.ស.ស. គឺមានកំណើន ០,៤៧ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៦,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៦។ **ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងប្រទេស** ត្រូវបានគ្រោងក្នុងកម្រិត ២,៨៩% នៃផ.ស.ស. គឺមានកំណើន ០,៣១ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ២២,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៦ និង**ចំណាយសម្រាប់ការទូទាត់ប្រាក់ខ្ចី** ត្រូវបានគ្រោងក្នុងកម្រិត ០,៧៥% នៃផ.ស.ស. គឺមានកំណើន ០,១២ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ៣០,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៦។ ទន្ទឹមនេះ **ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅ**

**ប្រទេស** ត្រូវបានគ្រោងក្នុងកម្រិត ៤,៨៦% នៃផ.ស.ស. គឺមានកំណើន ០,០៥ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១០,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៦។

- **ចំណាយចរន្តថវិកាថ្នាក់ជាតិ** ត្រូវបានវិភាជទៅតាមវិស័យនីមួយៗ ដូចខាងក្រោម៖
  - **វិស័យសង្គមកិច្ច** ត្រូវបានគ្រោងក្នុងកម្រិត ៥,៤៤% នៃផ.ស.ស គឺមានកំណើន ០,១ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១១.៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៦,
  - **វិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងក្នុងកម្រិត១,៤៥% នៃផ.ស.ស. គឺមានកំណើន ០,០១ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១០,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៦,
  - **វិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងក្នុងកម្រិត ១,៩១% នៃផ.ស.ស គឺថយចុះ ០,០៨ ពិន្ទុភាគរយនៃផ.ស.ស. ប៉ុន្តែមានកំណើន ៥,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៦,
  - **វិស័យការពារជាតិ សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងក្នុងកម្រិត ៣,៦០% នៃផ.ស.ស គឺមានកំណើន ០,១៥ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៤,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៦។
- ថវិការាជធានី ខេត្ត, ក្រុង ស្រុក ខណ្ឌ និង ឃុំ-សង្កាត់ ត្រូវកំណត់ត្រឹម ១,៥៩% នៃផ.ស.ស គឺមានកំណើន០,១២ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៩,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៦ ដែលក្នុងនោះថវិកាផ្ទាល់របស់រាជធានី ខេត្តសរុបមានប្រមាណ ០,៨៧% នៃផ.ស.ស. និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់រាជធានី ខេត្ត ស្មើនឹង ០,១៥% នៃផ.ស.ស., ថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់ក្រុង ស្រុក ខណ្ឌ ស្មើនឹង ០,១៥% នៃផ.ស.ស. ឬស្មើនឹង ១,០% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៦, និង ថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់មូលនិធិថវិកាឃុំ-សង្កាត់ឆ្នាំ២០១៧ ស្មើនឹង ០,៤៣% នៃផ.ស.ស. ឬស្មើនឹង ២,៨០% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៦។

### វិធានការដើម្បីបង្កើនប្រសិទ្ធភាពចំណាយ

១៦-ក្នុងក្របខ័ណ្ឌនៃគោលដៅចំណាយខាងលើនេះ រាជរដ្ឋាភិបាលនឹងជំរុញការអនុវត្តយុទ្ធសាស្ត្រ និង ក្របខ័ណ្ឌនៃវិធានការដើម្បី ***បង្កើនប្រសិទ្ធភាពចំណាយ*** ដូចខាងក្រោម៖

- បន្តបង្កើនការរៀបចំថវិកាឱ្យកាន់តែផ្សារភ្ជាប់ទៅនឹងគោលនយោបាយ តាមរយៈ ការបង្កើនប្រសិទ្ធភាព នៃការវិភាជថវិកាឱ្យកាន់តែមានមូលដ្ឋានច្បាស់លាស់ និងចំទិសដៅ ជាពិសេសការពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងពង្រីកការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញនិងអង្គភាពថវិកាពីចំនួន ២៥ ក្រសួង ស្ថាប័ន នៅឆ្នាំ២០១៦ ឱ្យឡើងដល់ ៣៦ ក្រសួង ស្ថាប័ន នៅឆ្នាំ២០១៧,
- ពង្រឹងការគ្រប់គ្រងឱ្យបានត្រឹមត្រូវនិងហ្មត់ចត់ និងការជ្រើសរើសមន្ត្រីរាជការ ពិសេសបុគ្គលិកជាប់កិច្ចសន្យា ក្នុងគោលបំណងផ្គូផ្គងធនធានហិរញ្ញវត្ថុដែលមាន និងតម្រូវការមន្ត្រីថ្មី,
- ពង្រឹងប្រសិទ្ធភាព និងតម្លាភាពនៃការប្រើប្រាស់ប្រាក់រង្វាន់ពីតម្លៃសេវាសាធារណៈ ទាំងសម្រាប់ការលើកទឹកចិត្តដល់មន្ត្រីរាជការដើម្បីលើកកម្ពស់ប្រសិទ្ធភាពសេវាសាធារណៈ និងសម្រាប់គាំទ្រដល់ការពង្រឹងយន្តការប្រមូលចំណូល។

- លើកកម្ពស់ប្រសិទ្ធភាពបច្ចេកទេស និងប្រតិបត្តិការចំណាយ តាមរយៈការបង្កើនតម្លៃនៃលុយ ដោយផ្តោតការយកចិត្តទុកដាក់លើភាពសមស្របនៃថ្លៃ, បរិមាណ, គុណភាព និង ភាពទាន់ពេល ក្នុងចំណាយថវិកា ទាំងចំណាយចរន្ត (ចំណាយបន្ទុកបុគ្គលិក និងចំណាយមិនមែនបន្ទុកបុគ្គលិក) និងចំណាយមូលធន,
- បន្តអនុវត្តឱ្យមានប្រសិទ្ធភាព និងតម្លាភាពនូវការងារលទ្ធកម្មនៃចំណាយសាធារណៈ និងពង្រឹងការអនុវត្តច្បាប់លទ្ធកម្មសាធារណៈ។
- សម្រាប់ក្រសួង **ស្ថាប័នអនុវត្តថវិកាកម្មវិធី រាល់ការទិញទំនិញ ឬ សេវា ដោយប្រើប្រាស់ថវិកា រដ្ឋទេយ្យបុរេប្រទាន គឺត្រូវបានអនុញ្ញាតឱ្យទិញតែពីក្រុមហ៊ុនដែលអនុវត្តបេបពិត**ក្នុងការប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំរបស់ខ្លួន,
- បន្តជំរុញការរិភាជថវិកាឱ្យដល់អង្គភាពអនុវត្តការងារផ្ទាល់ ទាំងនៅរដ្ឋបាលកណ្តាលនៃក្រសួងស្ថាប័ន និងនៅតាមបណ្តាមន្ទីរជំនាញរាជធានី ខេត្ត ក្នុងគោលដៅលើកកម្ពស់តម្លាភាពប្រសិទ្ធភាព និងការទទួលខុសត្រូវទាំងក្នុងក្របខ័ណ្ឌនៃការអនុវត្តចំណាយថវិកា ក៏ដូចជាលើលទ្ធផលការងារ,
- រឹតត្បិតមុខសញ្ញាចំណាយដែលមិនចាំបាច់ ឬមិនមែនអាទិភាព ដើម្បីសន្សំថវិកាយកទៅអនុវត្តសកម្មភាពអាទិភាព ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពនៃសេវាសាធារណៈ ព្រមទាំងបង្កើនផលិតភាព និងទ្រទ្រង់កំណើនសេដ្ឋកិច្ច ជាពិសេស ចំណាយលើមុខចំណាយទំនិញ និងសេវាមួយចំនួនដូចជា ប្រេងឥន្ធនៈ អគ្គិសនី សេវាទូរគមនាគមន៍ និងអ៊ីនធើណែត ព្រមទាំងត្រូវកាត់បន្ថយនូវបេសកកម្មទាំងក្នុងនិងក្រៅប្រទេស និងការបោះពុម្ពដែលមានគុណភាពប្រណីត ហើយមានតម្លៃខ្ពស់,
- ត្បិតត្បៀតលើចំណាយផ្នែកគម្រោងព័ត៌មានវិទ្យា (ICT) ទាំងផ្នែកចំណាយថវិកាចរន្ត ក៏ដូចជាថវិកាមូលធន/វិនិយោគ។ ប៉ុន្តែ ចាំបាច់ត្រូវពង្រឹងលើការគ្រប់គ្រង ប្រើប្រាស់ និងថែទាំប្រព័ន្ធសម្ភារៈ និងឧបករណ៍ដែលបានវិនិយោគរួចហើយ។
- បន្តធ្វើវិចារណកម្ម និងរឹតបន្តឹងចំណាយ ដើម្បីរក្សាឱនភាពថវិកាឱ្យនៅត្រឹមកម្រិតសមរម្យមួយដែលមិនប៉ះពាល់ចីរភាពថវិកា និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងដើម្បីបង្កើន **"លំហថវិកា"** សម្រាប់ដោះស្រាយតម្រូវការបន្ទាន់លើករណីប្រធានស័ក្តិ និងវិបត្តិផ្សេងៗ ឬតម្រូវការចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាល ព្រមទាំងការកាត់បន្ថយការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស,
- បន្តពង្រឹងការគ្រប់គ្រងចំណាយសាធារណៈ ជាពិសេសបន្តពង្រឹង និងជំរុញការកែលម្អការអនុវត្តថវិកា តាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយ, ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់, ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស, ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងឆមាស,
- បន្តគាំទ្រនិងជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុងដើម្បីបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកា, ការបន្តបង្កើនប្រសិទ្ធភាពគណនេយ្យភាពហិរញ្ញវត្ថុដែលសម្រេចបាន និង ជាពិសេស ការផ្សារភ្ជាប់ថវិកាទៅនឹងគោល

នយោបាយ ដែលជាជំហានទី៣នៃកម្មវិធីការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(២០១៦-២០២០),

- បន្តអនុវត្តនូវរាល់វិធានការគោលនយោបាយ ដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ (២០១៥-២០១៨) ក្នុងគោលបំណងបន្តរក្សាចីរភាពបំណុលសាធារណៈ រយៈពេលវែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប,
- បន្តគាំទ្រដល់សកម្មភាពការងារតាមដាន ត្រួតពិនិត្យ អធិការកិច្ចកម្រិតបច្ចេកទេសផ្នែកបច្ចេកទេស ដែលជាផែនការគាំទ្រដ៏មានសារៈសំខាន់ចំពោះដំណើរការនៃការធ្វើវិមជ្ឈការ ឬវិសហមជ្ឈការ សិទ្ធិ និងការទទួលខុសត្រូវលើការគ្រប់គ្រង និងចាត់ចែងអនុវត្តថវិកា។

**គ-ក្របខ័ណ្ឌតុល្យភាពថវិកាឆ្នាំ២០១៧**

១៧- ជារួម ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការផ្នែកចំណូល និង ផ្នែកចំណាយខាងលើ នឹងជួយបង្កើនអតិរេកថវិកាចរន្តឱ្យសម្រេចបានក្នុងរង្វង់ ៣,៤៤% នៃផ.ស.ស. និងកាត់បន្ថយឱនភាពថវិកាសរុបឱ្យនៅត្រឹម ៤,៨៩% នៃផ.ស.ស. នៅក្នុងឆ្នាំ២០១៧។ ប្រការនេះនឹងផ្តល់លទ្ធភាពកាន់តែច្រើនដល់រាជរដ្ឋាភិបាល សម្រាប់ដោះស្រាយសេចក្តីត្រូវការបន្ទាន់ក្នុងការងារអភិវឌ្ឍន៍ ក៏ដូចជាសម្រាប់ត្រៀមជាយថាហេតុចាំបាច់ផ្សេងទៀត ពិសេសត្រៀមសម្រាប់ដោះស្រាយទប់ទល់នឹងវិបត្តិ ដោះស្រាយបញ្ហាគ្រោះធម្មជាតិ ដោះស្រាយតម្រូវការចំណាយសម្រាប់ការការពារអធិបតេយ្យ និងបូរណភាពទឹកដី ព្រមទាំងសម្រាប់ឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងការអនុវត្តគោលនយោបាយថ្មី ដែលរាជរដ្ឋាភិបាលអាចដាក់ចេញនៅក្នុងឆ្នាំអនុវត្ត។

១៨- លើសពីនេះ ទំហំតុល្យភាពខាងលើនឹងជួយបង្កើន **"លំហថវិកា"** និងធានាបាននូវចីរភាពថវិកាដែលជាកត្តាគន្លឹះសម្រាប់ធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សម្រាប់ផ្តល់ភាពអនុគ្រោះដល់កំណើនសេដ្ឋកិច្ច ជាពិសេសបន្តបង្កើននូវប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាល ដើម្បីមានមូលដ្ឋានកាន់តែរឹងមាំសម្រាប់ទប់ទល់នឹងវិបត្តិខាងក្រៅ និងកាត់បន្ថយហានិភ័យផ្សេងៗ ព្រមទាំងកាត់បន្ថយការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស និងការគ្រប់គ្រងបំណុលប្រកបដោយចីរភាពក្នុងគោលដៅជំរុញការអភិវឌ្ឍនៅក្នុងល្បឿនលឿន។

## ៣. គោលការណ៍ និងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ២០១៧

### ៣.១- ការគ្រោងចំណូលថវិកាឆ្នាំ២០១៧

១៩- ការគ្រោងគិតចំណូលថវិកាចរន្ត អាស្រ័យលើប្រភពធនធាននៃផលិតផល ឬផលទុន ដែលជាប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងលក្ខខ័ណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ៖

- ចំណូលសារពើពន្ធ ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖
  - លទ្ធផលដែលសម្រេចនៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ (ឆ្នាំ២០១៦),
  - ចំណូលបន្ថែមដែលសង្ឃឹមថានឹងប្រមូលបាន ដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ គោលនយោបាយគយនិងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធ និងការប្រមូលបំណុលពន្ធដែលត្រូវទារ,
  - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ

- ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រា និងមូលដ្ឋានប្រមូលពន្ធ

• ចំពោះចំណូលមិនមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឱ្យមានផលទុន ដូចជា កិច្ចសន្យាសម្បទានគ្រប់ប្រភេទ កិច្ចសន្យាជួលសេវាកម្ម ការពង្រឹងនិងកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម។ល។

### ៣.២- ការគ្រោងចំណាយថវិកាឆ្នាំ២០១៧

២០- ចំពោះ**ក្រសួង ស្ថាប័ន អនុវត្តថវិកាកម្មវិធី** ព្រមទាំងមន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ការរៀបចំថវិកាឆ្នាំ២០១៧ នេះ ត្រូវយកចិត្តទុកដាក់លើប្រសិទ្ធភាពនៃការគ្រោងថវិកាទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព និង ជាពិសេស លទ្ធផល ឬធាតុចេញ (Output) ដែលនឹងសម្រេចបាន។ ប្រការនេះជាមូលដ្ឋានយ៉ាងសំខាន់សម្រាប់ធ្វើជាអំណះអំណាង និងគាំទ្រដល់ការរៀបចំ និងការចរចាថវិកា ព្រមទាំងជាមូលដ្ឋានសម្រាប់ធ្វើវិមជ្ឈការសិទ្ធិអំណាចនៃការអនុវត្តចំណាយ។ លើសពីនេះ ក្រសួង ស្ថាប័ន ដែលបានឆ្លងកាត់ការរៀបចំ និងអនុវត្តថវិកាកម្មវិធីរួចហើយ គួរផ្អែកលើបទពិសោធន៍ដែលមាន ចាប់ផ្តើមកែលម្អរចនាសម្ព័ន្ធកម្មវិធី និងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនឱ្យស៊ីសង្វាក់គ្នា ដើម្បីឱ្យការអនុវត្តមានភាពរលូនល្អ ហើយឈានទៅសម្រេចបានលទ្ធផលល្អ និងមានការទទួលខុសត្រូវកាន់តែច្បាស់លាស់។ ដោយឡែក ចំពោះ**ក្រសួង ស្ថាប័នអនុវត្តថវិកាមិនមែនកម្មវិធី** ការរៀបចំគម្រោងចំណាយថវិកា ត្រូវផ្អែកលើតម្រូវការចំណាយសម្រាប់អនុវត្តសកម្មភាពការងារជាអាទិភាពរបស់អង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលនៅក្នុងវង្វង់នៃលទ្ធភាពជាក់ស្តែងនៃថវិកា ដើម្បីសម្រេចគោលដៅនៃយុទ្ធសាស្ត្រអាទិភាព និងគោលបំណងគោលនយោបាយដែលបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ននីមួយៗ។ ***សូមរៀបចំគម្រោងថវិកាតាមតារាងគំរូដែលភ្ជាប់មកជាមួយសារាចរណែនាំនេះ។***

២១- គ្រប់**ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត** ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ការរៀបចំគម្រោងចំណាយចាំបាច់ត្រូវឆ្លុះបញ្ចាំងដោយលម្អិតទៅតាមមាតិកាសេដ្ឋកិច្ចនៃចំណាត់ថ្នាក់ថវិកា (ជំពូក គណនី និងអនុគណនី) ព្រមទាំងត្រូវវិភាគឱ្យបានច្បាស់លាស់អំពីតម្រូវការចំណាយតាមចង្កោមសកម្មភាព អនុកម្មវិធី និងកម្មវិធី ហើយត្រូវភ្ជាប់មកជាមួយនូវឯកសារសម្រាប់គាំទ្រ រួមទាំងឯកសារអង្កេតឬវិភាគតាមការចាំបាច់ និងពន្យល់អំពីភាពចាំបាច់នៃតម្រូវការចំណាយលើសកម្មភាពការងារនីមួយៗឱ្យបានគ្រប់ជ្រុងជ្រោយ ហើយឯកសារទាំងនេះក៏ជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យ ពិភាក្សា និងចរចាថវិកាផងដែរ។ លើសពីនេះការគណនាតម្រូវការចំណាយត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជា ចំណាយបន្ទុកបុគ្គលិក និងចំណាយមិនមែនបន្ទុកបុគ្គលិក ដែលត្រូវប៉ាន់ស្មានតម្លៃធាតុចូលដែលត្រូវការជាក់ស្តែង ដោយធៀបនឹងតម្រូវការប្រើប្រាស់ក្នុងឆ្នាំ២០១៥ និងការប៉ាន់ស្មាននៃការអនុវត្តក្នុងឆ្នាំ២០១៦ និងដោយផ្អែកលើថ្លៃឯកតាជាក់ស្តែងនៃទីផ្សារ ឬតាមគោលបេបកំណត់ជាដើម។

២២- ឈរលើមូលដ្ឋានតម្រូវការចំណាយ ដែលបានប៉ាន់ស្មាននៅក្នុងផែនការយុទ្ធសាស្ត្រថវិកា (២០១៧-២០១៩) ក្នុងការរៀបចំគម្រោងចំណាយថវិកាឆ្នាំ២០១៧ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញ

រាជធានី ខេត្តទាំងអស់ ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ត្រូវធានាឱ្យបាននូវការគ្រោងចំណាយរបស់ខ្លួន ដោយអនុលោមទៅតាម **គោលការណ៍** និង **បណ្តាវិធានការ** ដូចខាងក្រោម៖

**ក-ចំណាយបន្ទុកបុគ្គលិក(ជំពូក៦៤)៖** នាយកដ្ឋានបុគ្គលិកដែលជាសេនាធិការរបស់ក្រសួង ស្ថាប័ននីមួយៗ ត្រូវសម្របសម្រួលនិងគ្រោងចំណាយបន្ទុកបុគ្គលិកឱ្យបានសុក្រឹតទៅតាមគោលការណ៍នៃការតម្លើងបៀវត្សរបស់រាជរដ្ឋាភិបាល ព្រមជាមួយនឹងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា គឺចៀសវាងការគ្រោងបៀវត្ស ឬ បន្ទុកពាក់ព័ន្ធនឹងបុគ្គលិកនេះទុកចោលមិនប្រើប្រាស់ដូចឆ្នាំកន្លងមក។ គោលការណ៍សម្រាប់ការគ្រោងបន្ទុកបុគ្គលិកឆ្នាំ២០១៧ រួមមាន៖

- ត្រូវគ្រោងតាមមូលដ្ឋាននៃក្របខ័ណ្ឌ និងកម្រិតបៀវត្សឆ្នាំ២០១៦ គឺតាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រសួងមុខងារសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ២០១៦ ដោយ**តម្លើងបៀវត្សមូលដ្ឋាន**តាមតម្លៃកតាសន្ទស្សន៍ ១ ៩០០ រៀល ដោយគិតចាប់ពីខែមករា ដល់ ខែធ្នូ គឺមានកំណើនស្មើនឹង ១២% ក្នុងមួយឆ្នាំ,
- **ចំនួនក្របខ័ណ្ឌថ្មី**ត្រូវគ្រោងយ៉ាងច្រើន ស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណភាព ដែលត្រូវកាត់ចេញពីអង្គភាពសាមី ហើយត្រូវបញ្ជាក់ពីគោលដៅនៃតម្រូវការ និងមុខងារនៃមន្ត្រីដែលត្រូវជ្រើសរើសថែមនេះ។
- **ប្រាក់ឧបត្ថម្ភប្រពន្ធ** កូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ គឺត្រូវគ្រោងឱ្យកូនម្នាក់ចំនួន ១០ ០០០ រៀល ក្នុងមួយខែ និង ឧបត្ថម្ភដល់ប្រពន្ធចំនួន ១៥ ០០០ រៀល ក្នុងមួយខែ សម្រាប់រយៈពេល ១២ខែ ចាប់ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០១៧។
- ការតម្លើង**ប្រាក់បំណាច់មុខងារ**ជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ នឹងត្រូវបានអនុវត្តគិតចាប់ពីខែ មេសា ដល់ ខែធ្នូ ឆ្នាំ២០១៧ ទៅតាមកម្រិតនៃប្រាក់បំណាច់មុខងារឆ្នាំ២០១៦ ដូចតទៅ៖
    - **មន្ត្រីរាជការនៃក្រសួង ស្ថាប័នរដ្ឋបាលស៊ីវិល និងអង្គភាពក្រោមឱវាទ និង ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ** ៖ កម្រិតចាប់ពី ៥០០ ០០០ រៀល ចុះក្រោម បន្ថែមចំនួន១០០ ០០០រៀល និងកម្រិតចាប់ពី ៦៨០ ០០០ រៀល ឡើង បន្ថែមចំនួន ៤០ ០០០ រៀល ,
    - **ក្រសួងអប់រំ យុវជននិងកីឡា**៖ កម្រិតចាប់ពី ៦០០ ០០០ រៀល ចុះក្រោម បន្ថែមចំនួន ១០០ ០០០ រៀល និងកម្រិតចាប់ពី ៧០០ ០០០ រៀល ឡើង បន្ថែមចំនួន ៤០ ០០០ រៀល,
    - **ក្រសួងសុខាភិបាល**៖ កម្រិតចាប់ពី ៥០០ ០០០ រៀល ចុះក្រោម បន្ថែមចំនួន ១០០ ០០០ រៀល និងកម្រិតចាប់ពី ៧០០ ០០០ រៀល ឡើង បន្ថែមចំនួន ៤០ ០០០ រៀល,
    - **យោធិន និងនគរបាលជាតិ**៖ កម្រិតចាប់ពីរង្វង់ ៤០០ ០០០ រៀល ចុះក្រោម បន្ថែមចំនួន ១០០ ០០០ រៀល និងសម្រាប់កម្រិតផ្សេងទៀត បន្ថែមចំនួន ៤០ ០០០ រៀល ។

- ចំនួនមន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត ត្រូវគ្រោងមិនឱ្យលើសចំនួនដែលក្រសួងមុខងារសាធារណៈផ្តល់ជូន និងត្រូវប្រើប្រាស់ប្រកបដោយតម្លាភាព និងការទទួលខុសត្រូវស្របតាមគោលការណ៍ដែលមានចែងក្នុងអនុក្រឹតលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ ស្តីពី ការគ្រប់គ្រង និង ការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា។

**ខ- ចំណាយក្រៅបន្ទុកបុគ្គលិក (ជំពូក៦០ ការទិញ, ជំពូក៦១ សេវាកម្ម, ជំពូក៦២ អត្ថប្រយោជន៍សង្គម, ជំពូក៦៥ ឧបត្ថម្ភធន)** ជាសរុបសម្រាប់ឆ្នាំ២០១៧ ត្រូវគ្រោងក្នុងកម្រិតអតិបរមាត្រឹមកញ្ចប់ឥណទាននៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដោយអាទិភាពចំណាយឆ្នាំ២០១៧ ត្រូវបានបញ្ជាក់ច្បាស់លាស់ក្នុងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺ "ថវិកាឆ្នាំ២០១៧ ត្រូវផ្តោតជាសំខាន់លើការតម្លើងបៀវត្ស និងការវិនិយោគដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច"។ ***ក្នុងន័យនេះ ក៏មិនមែនមានន័យថា កញ្ចប់ថវិកាឆ្នាំ២០១៧ នឹងទទួលបានស្មើឆ្នាំ២០១៦ ដោយស្វ័យប្រវត្តិដែរ*** គឺទាមទារឱ្យក្រសួង ស្ថាប័ននីមួយៗ ត្រូវបង្កើនប្រសិទ្ធភាពនៃការធ្វើអាទិភាវូបនីយកម្មមុខចំណាយផង និងប្រសិទ្ធភាពប្រតិបត្តិការចំណាយផង។ ជាមួយគ្នានេះ ក្រសួង ស្ថាប័ន ដែលមានសមិទ្ធិកម្មល្អលើការងារកែទម្រង់ នឹងត្រូវទទួលបានការលើកទឹកចិត្ត។ ដូច្នេះ ***គ្រប់ក្រសួង ស្ថាប័ន ត្រូវធ្វើអាទិភាវូបនីយកម្មនៃអាទិភាពគោលនយោបាយ និងថ្លឹងថ្លែងបែងចែកថវិការវាងកម្មវិធីនីមួយៗ ជាពិសេសកម្មវិធីស្នូលរបស់ក្រសួង ស្ថាប័ន ដើម្បីសម្រេចគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។ ក្រសួង ស្ថាប័នត្រូវពិនិត្យលទ្ធភាពនៃការផ្ទេរធនធានថវិកាពីកម្មវិធីមួយ ទៅកម្មវិធីមួយទៀត ឬពីអង្គភាពថវិកាមួយ ទៅអង្គភាពថវិកាមួយទៀត នៅក្នុងក្រសួង ស្ថាប័នតែមួយឱ្យអស់លទ្ធភាព ព្រមជាមួយនឹងការថ្លឹងថ្លែងគុណភាពនៃការបែងចែកធនធាន និងសិទ្ធិអំណាច ទៅតាមនិងរវាងអង្គភាពថវិកានីមួយៗក្នុងក្របខ័ណ្ឌពិដានកញ្ចប់ថវិកាដែលបានកំណត់ និងត្រូវចៀសវាងការបំប៉ោងចំណាយដោយមូលហេតុនៃការអនុវត្តថវិកាកម្មវិធី***។ ក្នុងន័យនេះដែរ ចំណាយក្រៅបន្ទុកបុគ្គលិក ត្រូវគ្រោងដោយឈរលើគោលការណ៍ ដូចខាងក្រោម៖

- **ការបន្តអនុវត្តសកម្មភាពការងារកំពុងដំណើរការ** ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវគ្រោងចំណាយដោយផ្អែកលើបរិមាណជាតុចូលដែលធ្លាប់ប្រើក្នុងឆ្នាំ២០១៥ កន្លងទៅ និងការប៉ាន់ស្មានអនុវត្តនៅក្នុងឆ្នាំ២០១៦ នេះ និងដោយផ្អែកលើតម្លៃឯកតាជាក់ស្តែងលើទីផ្សារ ហើយចៀសវាងការបង្កើនបរិមាណជាតុចូលលើសពីតម្រូវការដែលធ្លាប់មាន។ ទន្ទឹមនេះ ត្រូវគ្រោងថវិកាប្រកបដោយលក្ខណៈត្បិតត្បៀត និងសន្សំសំចៃ ពិសេសលើមុខសញ្ញាទិញឧបករណ៍ សម្ភារបរិក្ខារទំនើប គ្រឿងសង្ហារឹមប្រណីត ការបោះពុម្ពប្រណីត សម្ភារការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវអធឹកអធម បេសកកម្មក្នុងនិងក្រៅប្រទេស ព្រមទាំងសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជា សោហ៊ុយទូរគមនាគមន៍ អគ្គិសនី និងទឹកជាដើម។ លើសពីនេះ ត្រូវលុបបំបាត់ការខ្ជះខ្ជាយចំណាយ ឬបំប៉ោងចំណាយលើការរៀបចំកិច្ចប្រជុំ សិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ ការតាំងពិពណ៌ ដោយឡែកកិច្ចប្រជុំពាក់ព័ន្ធនឹងអាស៊ាន គឺអនុញ្ញាតសម្រាប់តែកិច្ចប្រជុំដែលត្រូវវេន ចំពោះកិច្ចប្រជុំដែលមិនចំវេន គឺត្រូវសុំគោលការណ៍អនុញ្ញាតពីប្រមុខរាជរដ្ឋាភិបាល។ ចំពោះកិច្ចប្រជុំ ឬ

សិក្ខាសាលា ដែលគ្រោងក្នុងថវិកា ត្រូវបង្ហាញពីភាពចាំបាច់ ភាពសមរម្យនៃការរៀបចំទាំងក្នុងទំហំ និងតម្លៃ។

- ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវពិនិត្យឡើងវិញ និងត្រូវកាត់ចេញនូវមុខចំណាយណាដែលមានតម្រូវការសម្រាប់តែក្នុងឆ្នាំ២០១៦ ហើយលែងត្រូវការនៅក្នុងឆ្នាំ២០១៧ ឬដែលសកម្មភាពការងារដែលនឹងត្រូវបញ្ចប់នៅក្នុងឆ្នាំ២០១៦,
- **ថវិកាដែលកាត់ចេញពីមុខចំណាយ ឬសកម្មភាពការងារដែលត្រូវបានបញ្ចប់ មិនមែនជាកម្មវត្ថុនៃការវិភាជឡើងវិញជាស្វ័យប្រវត្តិឡើយ គឺលុះត្រាតែមានសកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មី** ដែលត្រូវអនុវត្ត ហើយដែលបានលើកឡើងក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៧ ហើយមានយុត្តិការអំពីភាពចាំបាច់ និងបន្ទាន់ ដោយត្រូវផ្តល់ការពន្យល់ និងផ្តល់អំណះអំណាងឱ្យបានត្រឹមត្រូវ និងច្បាស់លាស់សម្រាប់សកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មី។
- ក្នុងការគ្រោង និងវិភាជថវិកា ត្រូវបង្កើនវិមជ្ឈការការផ្ទេរចំណាយរដ្ឋបាលជាប្រចាំ និងសោហ៊ុយបេសកកម្មក្នុង និងក្រៅប្រទេស ជាដើម ទៅតាមអង្គភាពថវិកា ឱ្យបានក្នុងកម្រិតអតិបរមា។
- ចំពោះតម្រូវការចំណាយបន្ថែមលើសពីពិដានកញ្ចប់ថវិកា ត្រូវឆ្លងការចរចាកម្រិតថ្នាក់ដឹកនាំក្រសួង ឬក្នុងករណីចាំបាច់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងស្នើសុំការសម្រេច ឬស្នើសុំការសម្រេចឡើងវិញពីប្រមុខរាជរដ្ឋាភិបាល បន្ទាប់ពីមានឯកសារទស្សនាទាន ឯកសារយុត្តិការស្តីពីគោលនយោបាយ និងកម្មវិធី ឬមុខសញ្ញាចំណាយ និងតម្លៃច្បាស់លាស់។ សម្រាប់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានភារកិច្ចប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំដាក់ចេញវិធានការដាក់ស្តែងបន្ថែម សម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ដែលការគ្រោងចំណូលដោយកត្តាអត្តនោម័តគឺជាកម្មវត្ថុនៃការរឹតត្បិត ឬលើកទឹកចិត្តចំណាយ សម្រាប់ការគ្រោងកញ្ចប់ថវិកាប្រចាំឆ្នាំ ។
- សម្រាប់ចំណាយវិនិយោគ ត្រូវមានក្របខ័ណ្ឌនៃការវិភាជដោយឡែក ដោយអនុលោមតាមអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ចំពោះក្រសួង ស្ថាប័ន ដែលត្រូវទទួលបានការវិភាជថវិកាជាទៀងទាត់ គម្រោងអាទិភាពលម្អិតគឺជាកម្មវត្ថុនៃកិច្ចពិភាក្សាក្រោមយន្តការអន្តរក្រសួងដែលមានស្រាប់ ឬដែលនឹងត្រូវបង្កើតឡើង។

• ក្នុងគោលបំណងផ្តល់ភាពទន់ភ្លន់ចំពោះក្រសួង ស្ថាប័ន និងមន្ទីរជំនាញ ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្នុងការរៀបចំថវិកា ពិសេស ដើម្បីឆ្លើយតបទៅនឹងតម្រូវការដាក់ស្តែងសម្រាប់អនុវត្តសកម្មភាពការងារថ្មី ការកំណត់កញ្ចប់ថវិកាអតិបរមាតាមបណ្តាជំពូកខាងលើ ដោយផ្អែកលើមូលដ្ឋាននៃឥណទានថវិកាឆ្នាំ២០១៦ អាចត្រូវបានអនុញ្ញាតឱ្យធ្វើការកែសម្រួលតាមតម្រូវការដាក់ស្តែង ដោយរក្សាកញ្ចប់សរុបនៃឥណទានថវិកាក្រៅពីបន្ទុកបុគ្គលិកទាំងអស់យ៉ាងច្រើនត្រឹមកម្រិតឆ្នាំ២០១៦។ ប៉ុន្តែ ការរៀបចំគម្រោងចំណាយលម្អិតតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់ដើម្បីបង្កើនសុក្រឹតភាពនៃការគ្រោង និងវិភាជ

ថវិកា ព្រោះ ***ដូចជាឆ្នាំមុនៗដែរ ការផ្ទេរនិយ័តភាពឥណទានថវិកាផ្ទៃក្នុងរបស់ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត អាចនឹងត្រូវអនុញ្ញាតឱ្យធ្វើបានទាល់តែចាប់ពីត្រីមាសទី២ សម្រាប់ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធី និងចាប់ពីត្រីមាសទី៣ សម្រាប់ក្រសួង ស្ថាប័នអនុវត្តថវិកាមិនមែនកម្មវិធី*** *ហើយត្រូវផ្អែកលើហេតុផល និងលទ្ធផលការងារ។*

២៣- ទន្ទឹមនឹងការគ្រោងចំណាយដោយផ្អែកលើគោលការណ៍នៃការកំណត់កញ្ចប់ និងវិធានការខាងលើ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធ្វើការ **គណនា តម្រូវការចំណាយនៃជំពូកក្រៅពីបន្ទុកបុគ្គលិក** រួមមាន ជំពូក៦០ ជំពូក៦១ ជំពូក៦២ ជំពូក៦៣ និងជំពូក៦៥ ដោយផ្អែកលើមូលដ្ឋានពីរបន្ថែមទៀត ដូចខាងក្រោម៖

- ***កំណត់ចំណាយជាប្រចាំ ហើយបង្កើតមូលដ្ឋានគណនាតម្រូវការចំណាយនេះ ឱ្យបានច្បាស់លាស់។*** ចំណាយជាប្រចាំ គឺជាចំណាយដែលមានតម្រូវការជាប្រចាំ និងត្រូវការចំណាយជារៀងរាល់ឆ្នាំ ដែលរួមមាន ការចំណាយសម្ភារផ្គត់ផ្គង់ និង ថែទាំជាប្រចាំ (ដូចជាសម្ភារផ្គត់ផ្គង់ ថែទាំតូចតាចសម្រាប់ថែទាំអគារ ប្រាសាទ ផ្លូវថ្នល់ ស្ពាន លូ រថយន្ត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) និងសម្ភារផ្គត់ផ្គង់រដ្ឋបាលជាប្រចាំ (ដូចជា សម្ភារការិយាល័យ ការបោះពុម្ព ការទិញឯកសារ សម្ភារបរិក្ខារប្រើប្រាស់ជាប្រចាំ ស្បៀងអាហារ និងឯកសណ្ឋានសម្រាប់ក្រសួង ស្ថាប័នមួយចំនួនដែលត្រូវការប្រើប្រាស់ជាប្រចាំ ព្រមទាំងការចំណាយលើអគ្គិសនី ទឹក ប្រេងឥន្ធនៈ និងទូរស័ព្ទជាដើម)។ ប្រភេទចំណាយជាប្រចាំនេះ គួរកំណត់ឱ្យបានច្បាស់លាស់ និងបង្កើតមូលដ្ឋានគណនាឱ្យបានត្រឹមត្រូវ និងសមស្របទៅតាមតម្រូវការជាក់ស្តែង ព្រមទាំង**វិភាជទៅតាមអង្គភាពថវិកា នាយកដ្ឋាន ឬអង្គភាពជំនាញដោយផ្ទាល់។**
- ***កំណត់ចំណាយមិនជាប្រចាំ ហើយត្រូវមានគម្រោងច្បាស់លាស់បញ្ជាក់ពីតម្រូវការ និងប្រសិទ្ធភាពនៃការប្រើប្រាស់ចំណាយមិនប្រចាំនេះ ព្រមទាំងមូលដ្ឋានគណនាតម្រូវការចំណាយនេះឱ្យបានច្បាស់លាស់។*** ចំណាយមិនជាប្រចាំគឺជាចំណាយដែលមិនត្រូវការចំណាយ ជារៀងរាល់ឆ្នាំដែលរួមមានការចំណាយបំពាក់ឧបករណ៍សម្ភារការិយាល័យ ឧបករណ៍សម្ភារដឹកជញ្ជូន សម្ភារបរិក្ខារបច្ចេកទេស គ្រឿងសង្ហារឹម និងឧបករណ៍សម្ភារប្រើប្រាស់ផ្សេងៗ ដែលជាចំណាយមិនត្រូវទិញប្រចាំឆ្នាំព្រមទាំងចំណាយសម្រាប់ការជួសជុល បោះពុម្ព កិច្ចប្រជុំ សិក្ខាសាលា និងបេសកកម្មមួយចំនួនដែលមិនមែនជាសកម្មភាពជាប្រចាំឆ្នាំ។ ប្រភេទចំណាយមិនជាប្រចាំនេះគួរកំណត់ឱ្យបានច្បាស់លាស់មានគម្រោង និងកាលវិភាគច្បាស់លាស់សម្រាប់ការចំណាយប្រភេទនេះ សម្រាប់រយៈពេលមធ្យម និងមានមូលដ្ឋាន គណនាតម្រូវការចំណាយ ត្រឹមត្រូវទៅតាមតម្រូវការជាក់ស្តែងរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំង គ្រឹះស្ថានសាធារណៈរដ្ឋបាល។

២៤- ជាមួយគ្នានេះដែរ ដើម្បីបង្កើនប្រសិទ្ធភាពចំណាយនៅដំណាក់កាលរៀបចំ និងចរចាថវិកា **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឱ្យកាត់ចេញនូវថវិកាប្រភេទចំណាយមិនជាប្រចាំផ្ទៃក្នុង**ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ។ ទំហំឥណទានដែលនៅសល់ក្នុងក្របខ័ណ្ឌពិដាននេះ អាចជាកម្មវត្ថុនៃការវិភាជសម្រាប់កែលម្អ ឬបង្កើនប្រសិទ្ធភាពនៃកម្មវិធី

ដែលមានស្រាប់ ឬសម្រាប់កម្មវិធីបម្រើឱ្យគោលនយោបាយថ្មី នៅក្នុងក្រសួង **ស្ថាប័នដដែល ឬ ទៅ ក្រសួង ស្ថាប័នមួយទៀត ឬពីមន្ទីរជំនាញនៃក្រសួងមួយ ទៅមន្ទីរជំនាញនៃក្រសួងមួយទៀតបាន** ក្នុងក្របខ័ណ្ឌនៃវិស័យចំណាយតែមួយ។

២៥-ទន្ទឹមនេះ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលអនុវត្តថវិកាកម្មវិធី ត្រូវតែផ្តល់របាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាកម្មវិធីឆ្នាំ២០១៥ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្ត ហើយក៏ជាកម្មវត្ថុសម្រាប់ការលើកទឹកចិត្ត ឬ ការកាត់បន្ថយគម្រោងចំណាយឆ្នាំ២០១៧ ផងដែរ។ នៅពេលពិភាក្សា និងចរចាថវិកា ក្រសួង ស្ថាប័ននីមួយៗត្រូវរៀបចំជាបទបង្ហាញអំពីរបាយការណ៍សមិទ្ធកម្មឆ្នាំ២០១៥ របាយការណ៍សមិទ្ធកម្មពាក់កណ្តាលឆ្នាំ២០១៦ និងការគ្រោងលទ្ធផលរំពឹងទុក សម្រាប់ឆ្នាំ២០១៧។

២៦- ទន្ទឹមនេះដែរ ត្រូវផ្អែកលើមូលដ្ឋាននៃថវិកាឆ្នាំ២០១៦ ដែលកំពុងអនុវត្តស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ក្នុងការរៀបចំថវិកាឆ្នាំ២០១៧ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល អាចពិនិត្យផងដែរទៅដល់បម្រែបម្រួលនៃថវិកាក្នុងអំឡុងពេលអនុវត្ត ដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម៖

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងអនុវត្ត ដូចជាការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬ ពីជំពូកមួយទៅជំពូកមួយទៀត ផ្ទៃក្នុងឬពីកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៅកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៀត ដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង ស្ថាប័ន ព្រមទាំងមន្ទីរជំនាញរាជធានី ខេត្ត មានការប្រែប្រួល,
- ការផ្ទេរឥណទានថវិកាបន្ថែម សម្រាប់ផលប្រយោជន៍របស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត។

២៧- ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលស្ថិតក្រោមក្រសួងស្ថាប័ននីមួយៗ ត្រូវពង្រឹងតួនាទីក្រុមការងារថវិការបស់ខ្លួន និងត្រូវផ្តល់កិច្ចសហការគ្នាទៅវិញទៅមកជាប្រចាំឱ្យបានពេញលេញក្នុងកម្រិតបច្ចេកទេស ជាមួយក្រុមការងារថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) សំដៅបង្កើនប្រសិទ្ធភាព និងភាពទាន់ពេលវេលានៃការរៀបចំថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ននីមួយៗ។

### ៣.៣- កាលវិភាគនៃការរៀបចំគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០១៧

២៨- រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលានូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។ នៅក្នុងកិច្ចដំណើរការនេះ ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៦ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមពិភាក្សានិងចរចាគម្រោងថវិកាជាមួយក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងធ្វើការបូកសរុបចំណូល-ចំណាយ រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ។ **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ និង**

**ធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ហើយផ្ញើជូនគណៈរដ្ឋមន្ត្រីឱ្យបាននៅក្នុងសប្តាហ៍ទី១ នៃខែតុលា ឆ្នាំ២០១៦ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ហើយផ្ញើជូនរដ្ឋសភាឱ្យបានក្នុងសប្តាហ៍ទី១ នៃខែវិច្ឆិកា ឆ្នាំ២០១៦ ដើម្បីស្ថាប័ននីតិប្បញ្ញត្តិមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់នេះ ឱ្យបានមុនថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៦។**

២៩- **ឯកសារផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៧ និងគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០១៧** ដែលក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល បានផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាមូលដ្ឋានចាំបាច់មិនអាចខ្វះបានសម្រាប់**ការចរចាថវិកាកម្រិតបច្ចេកទេស/ជំនាញ** និង **ការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង** ដើម្បីធ្វើយុត្តិកម្មកញ្ចប់ថវិការបស់ខ្លួន។ **ការចរចាថវិកាកម្រិតបច្ចេកទេស និង កម្រិតថ្នាក់ដឹកនាំនេះ នឹងត្រូវពិភាក្សាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច (ជំពូក គណនី និងអនុគណនី) និង/ឬ តាមចំណាត់ថ្នាក់កម្មវិធី (កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព)** លើមូលដ្ឋាននៃគោលការណ៍និងវិធានការនៃការគ្រោងថវិកាដូចបានលម្អិតខាងលើ ដើម្បីធានាប្រសិទ្ធភាពនៃការវិភាជថវិកាក្នុងកម្រិតនៃពិដានកញ្ចប់ថវិកាឆ្នាំ២០១៧ ដែលបានកំណត់និងក្នុងកម្រិតលទ្ធភាពថវិកាជាតិទ្រទ្រង់បាន។ ដូច្នេះ ក្នុងករណីដែលក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលណាមួយមិនបានបំពេញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់ទៅតាមគោលការណ៍ និងតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្តនោះឱ្យបានទាន់ពេលវេលា ដើម្បីធ្វើការបំពេញបន្ថែម ហើយប្រសិនបើ នៅតែមិនអាចបំពេញបានទេ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការយកមូលដ្ឋាន នៃឥណទានថវិកាឆ្នាំ២០១៦ ដោយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូកខាងលើ សម្រាប់កំណត់គម្រោងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរជំនាញ រាជធានី ខេត្តនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ឱ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ។ តួលេខគម្រោងចំណូល-ចំណាយថវិកា ត្រូវសរសេរជាលេខអន្តរជាតិ (1, 2, 3...) ហើយឯកតាទាបបំផុតគិតត្រឹម 0,1 លាន រៀល។

## ៤. សេចក្តីសន្និដ្ឋាន

៣០- ខ្លឹមសារនៃសារាចរណែនាំនេះ បានកំណត់ក្របខ័ណ្ឌ និងវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេស ក្នុងការគ្រោងចំណូល និងចំណាយចាំបាច់ សម្រាប់ជាមូលដ្ឋានដល់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន សំដៅធ្វើយ៉ាងណាសម្រេចឱ្យបានជោគជ័យនូវគោលបំណងនៃគោលនយោបាយ និងកម្មវិធី/យុទ្ធសាស្ត្រអាទិភាពរបស់ខ្លួន ដើម្បីរួមចំណែកសម្រេចឱ្យបានគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល គឺរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលវែងប្រកបដោយចីរភាពក្នុងរង្វង់ ៧% និង កាត់បន្ថយភាពក្រីក្រឱ្យបានលើស ១% ក្នុងមួយឆ្នាំៗ ព្រមទាំងបន្តរក្សាឱ្យបាននូវស្ថិរភាព នយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានគ្រឹះ និងចាំបាច់បំផុត ក្នុងការឈានទៅសម្រេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាល គឺភាពសុខដុមមនោសង្គម និងសុខុមាលភាពប្រជាជន។

៣១- ទោះជាយ៉ាងណាក៏ដោយ ដើម្បីឱ្យគោលដៅទាំងឡាយដែលបានដាក់ចេញក្នុងសារាចរនេះ អាចអនុវត្តសម្រេចបានជោគជ័យ ថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័ន និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ចាំបាច់

ត្រូវខិតខំថែមទៀតប្រកបដោយឆន្ទៈប្តូរប្តេជ្ញ ពិសេស ត្រូវតែផ្លាស់ប្តូរឥរិយាបទនិងផ្នត់គំនិតក្នុងការរៀបចំថវិកា ដោយខិតខំគោរពឱ្យបានខ្ជាប់ខ្ជួនតាមក្របខ័ណ្ឌ និងបណ្តាវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេសទាំងឡាយ ទាំងផ្នែកចំណូល និងផ្នែកចំណាយ ដែលកំណត់ដោយសារាចរណែនាំនេះ។ ទន្ទឹមនេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវបន្តជំរុញការលើកកម្ពស់អភិបាលកិច្ចល្អនៅក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ ដើម្បីមិនត្រឹមតែអាចបង្កើនសក្តានុពលនៃតួនាទីរបស់ថវិកា ដែលជាឧបករណ៍សម្រាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេស **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣** ប៉ុណ្ណោះទេ ថែមទាំងអាចធ្វើជាជន្ទល់ដ៏រឹងមាំសម្រាប់ទ្រទ្រង់ដល់ការដ្ឋានកម្មវិធីកែទម្រង់ដទៃទៀត ដោយរួមទាំងដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋផងដែរ។

៣២- ពេលទទួលសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំង គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំជាបន្ទាន់នូវគម្រោងចំណូល-ចំណាយថវិការបស់ខ្លួន សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកា) **ចំនួនពីរច្បាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦** ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាថវិកាកម្រិតបច្ចេកទេស/ជំនាញ និងបូកសរុប ហើយអាចចាប់ផ្តើមដំណើរការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ទាន់ពេលវេលាកំណត់។ ក្នុងការអនុវត្តសារាចរណែនាំនេះ ប្រសិនបើក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំង គ្រឹះស្ថានសាធារណៈរដ្ឋបាល មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា)។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
"ដើម្បីជូនជ្រាប"
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
-គ្រប់មន្ទីរជំនាញរាជធានី ខេត្ត
"ដើម្បីមុខការ "
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០០ ........សហវ.ប្រក

**ប្រកាសអន្តរក្រសួង**
**ស្តីពី**
**ការបង្កើតរង្វាន់ថវិកាសម្រាប់ឆ្នាំ២០១៦**
**របស់នាយកដ្ឋានសំណង់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេ ប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល ប្រការ ៤ ប្រការ ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសអន្តរក្រសួងលេខ ១៦២ អយក.ប្រក ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៥ ស្តីពីការដាក់ឲ្យអនុវត្តអង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ ១ ៖-**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក ៦០ "ការទិញ", ជំពូក៦១ "សេវាកម្ម នៅនាយកដ្ឋានសំណង់នៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ ថ្មីនៃប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល ប្រការ ៤ ប្រការ ៥ ប្រការ ១៤ ប្រការ ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ ។

**ប្រការ ២ ៖-**

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ។

**ប្រការ ៣ ៖-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤ ៖-**

